ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥

## ខេត្តក្រចេះ


រៀបចំដោយ ៖ មន្ទីរទេសចរណ៍ខេត្តក្រចេះ

សហការដោយ៖ នាយកដ្ឋានផែនការអភិវឌ្ឍន៍ នៃក្រសួងទេសចរណ៍

# សារលិខិត

## ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តក្រចេះ

ក្នុងនាមគណៈអភិបាលខេត្ត គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានដាក់បង្ហាញជូននូវផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មឆ្នាំ២០២១-២០២៥ ខេត្តក្រចេះ ដែលជាឯកសារគ្រឹះដ៏មានសារៈសំខាន់ និងជាត្រីវិស័យមួយក្នុងការចង្អុលបង្ហាញពីក្របខណ្ឌអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តក្រចេះ។

**ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មឆ្នាំ២០២១-២០២៥ ខេត្តក្រចេះ** នេះ មានបញ្ជាក់ពីទិសដៅអភិវឌ្ឍន៍ទេសចរណ៍ច្បាស់លាស់ចំនួន៨ចំណុចធំៗ ដោយមានបង្ហាញយ៉ាងលំអិតអំពីផែនការសកម្មភាពលើគម្រោងអាទិភាពទាំងឡាយក្នុងការអភិវឌ្ឍទេសចរណ៍ ហើយផែនការអភិវឌ្ឍន៍នេះគឺជាទស្សនៈវិស័យរួមមួយដែលចង្អុលបង្ហាញពីការអភិវឌ្ឍខេត្តតាមរយៈគម្រោងអាទិភាពប្រាំឆ្នាំរបស់វិស័យទេសចរណ៍សំដៅលើការអភិរក្សធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពសហគមន៍ផងដែរ។

ផ្អែកលើមូលដ្ឋានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិដ៏សម្បូរបែប និងជាសក្តានុពលធនធានទេសចរណ៍សំខាន់ដូចជា ព្រះវិហារវត្តសសរ១០០ អន្លង់ផ្សោតកាំពី សំណង់អគារសល់ពីសម័យបារាំង និងសកម្មភាពផលិតវត្ថុអនុស្សាវរីយ៍ជាដើម។ ក្នុងខ្លឹមសារនៃ **ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មឆ្នាំ ២០២១-២០២៥ ខេត្តក្រចេះ** បានកំណត់យ៉ាងជាក់លាក់ពីចក្ខុវិស័យ គោលបំណង គោលដៅ ទិសដៅអភិវឌ្ឍន៍ទេសចរណ៍ និងផែនការសកម្មភាពជាអាទិភាពលើការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងចំពោះ **ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្ន-កម្មឆ្នាំ២០២១-២០២៥ ខេត្តក្រចេះ** និងសូមដាក់ជូននូវផែនការដ៏ល្អនេះសម្រាប់ប្រើប្រាស់ជាត្រីវិស័យក្នុងការអភិវឌ្ឍទេសចរណ៍សម្រាប់ខេត្ត។ ខ្ញុំសូមអំពាវនាវឲ្យមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ មន្ទីរអង្គភាពជុំវិញខេត្ត ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ចូលរួមលើកស្ទួយការអភិវឌ្ឍធនធានមនុស្ស ផលិតផលទេសចរណ៍ និងសម្បទាទេសចរណ៍ថ្មីៗ ការពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ ក៏ដូចជាការចូលរួមអភិរក្សបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ការអភិរក្សធនធានធម្មជាតិ និងការការពារបរិស្ថាន ដើម្បីលើកកម្ពស់កិត្យានុភាព និងកំណើនសេដ្ឋកិច្ចក្នុងមូលដ្ឋាន រួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋក្នុងតំបន់ផងដែរ៕

ថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅក្រចេះ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១
អភិបាលខេត្ត

វ៉ា ថន

# ផែនទីទេសចរណ៍ ខេត្តក្រចេះ
## TOURISM MAP OF KRATIE



## I. សេចក្តីផ្តើម

វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធគឺជាវិស័យអាទិភាពមួយត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងគោលដៅដើម្បីបង្កើនការងារសមធម៌ និងប្រសិទ្ធភាពសំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦របស់រដ្ឋសភា។ ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់រួមចំណែកយ៉ាងសកម្មក្នុងកិច្ចការអភិវឌ្ឍ ថែរក្សាការពារអភិរក្សសម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងរួមចំណែកទប់ស្កាត់បម្រែបម្រួលអាកាសធាតុ។ វិស័យទេសចរណ៍បានក្លាយទៅជាផ្នែកអាទិភាពមួយនៃសេដ្ឋកិច្ចជាតិ ជាកម្លាំងចលករនៃការអភិវឌ្ឍសង្គមនៃប្រទេសជាច្រើនក្នុងតំបន់ និងសកលលោកដែលក្នុងនោះរួមមានព្រះរាជាណាចក្រកម្ពុជាយើងផងដែរ។

ការផ្សព្វផ្សាយទេសចរណ៍ "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ" មានសក្តានុពលយ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ដោយឈរលើប្រភពធនធាន "វប្បធម៌ និងធម្មជាតិ" ក្នុងនោះក្រសួងទេសចរណ៍បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០ ដោយមានចក្ខុវិស័យដើម្បីជំរុញអភិវឌ្ឍទេសចរណ៍កម្ពុជាដែលជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាពដោយស្រូបយកផលប្រយោជន៍ពីវិស័យទេសចរណ៍រួមចំណែកកសាងនូវសេដ្ឋកិច្ចសង្គម បង្កើនការងារ និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងន័យនេះដែរ ការអភិវឌ្ឍទេសចរណ៍គឺត្រូវសម្រេចឲ្យបានទាំងបរិមាណ និងគុណភាព ត្រូវប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសក្តានុពលដែលមានប្រកបដោយមនសិការ និងត្រូវគោរពដល់គុណតម្លៃវប្បធម៌សង្គមជាតិទាំងមូលផងដែរ។

ការអភិវឌ្ឍទេសចរណ៍ទាមទារឲ្យមានយុទ្ធសាស្ត្រគ្រប់គ្រងគោលដៅទាក់ទាញទេសចរ។ សម្រាប់តំបន់គោលដៅទាក់ទាញទេសចរអាទិភាពចំនួន៤៖ ភ្នំពេញ និងតំបន់ជុំវិញ សៀមរាបអង្គរ និងតំបន់ជុំវិញ តំបន់ឆ្នេរ និងតំបន់ភូមិភាគឦសានដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកធ្វើជាប៉ូលអាទិភាពសម្រាប់ការអភិវឌ្ឍដើម្បីទាក់ទាញទេសចរជាតិ អន្តរជាតិ ក្នុងនោះដែរក្រសួងទេសចរណ៍សហការជាមួយគ្រប់ស្ថាប័នភាគីពាក់ព័ន្ធបាននិងកំពុងរៀបចំផែនការអភិវឌ្ឍទេសចរណ៍តំបន់ប៉ូលអាទិភាពទាំងនេះ ជាពិសេសបានយកចិត្តទុកដាក់រៀបចំផែនការអភិវឌ្ឍទេសចរណ៍នៅតាមបណ្តារាជធានី-ខេត្តនីមួយៗផងដែរ។

ខេត្តក្រចេះជាខេត្តមួយស្ថិតនៅក្នុងភូមិភាគឦសានប្រកបដោយសក្តានុពលទេសចរណ៍ដ៏សំបូរបែប និងមានលក្ខណៈពិសេសដោយមានស្ថានភាពភូមិសាស្ត្រមានលក្ខណៈអំណោយផលខ្លាំង វិសេសវិសាល ប្រភពធនធានធម្មជាតិដែលមានលក្ខណៈល្អប្លែកជាសម្បត្តិវប្បធម៌ដ៏ប្រណីតបម្រើឲ្យវិស័យទេសចរណ៍នៅក្នុងខេត្តនេះទាំងមូល។ ដោយមើលឃើញពីសក្តានុពលទាំងអស់នេះហើយវិស័យទេសចរណ៍ត្រូវបានចាត់ជាវិស័យអាទិភាពក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ខេត្តនិងដើម្បីជំរុញការឆ្លើយតបទៅតាមតម្រូវការរបស់ភ្ញៀវទេសចរជាតិ អន្តរជាតិនាពេលបច្ចុប្បន្ន និងពេលអនាគតដែរ។

ការរៀបចំផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តក្រចេះ គឺជាឯកសារគន្លឹះមួយដើម្បីណែនាំ និងបង្ហាញពីវិធីសាស្ត្រក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តក្រចេះសំដៅឲ្យការអនុវត្ត

ការងារប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាពដោយគិតគូរពីផលប៉ះពាល់ផ្នែកបរិស្ថាន ក៏ដូចជាការចូលរួមអំពាវនាវគៀងគរដល់អ្នកវិនិយោគ អង្គការក្រៅរដ្ឋាភិបាល ផ្នែកសាធារណៈ វិស័យឯកជន ចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាពិសេសដោះស្រាយបញ្ហាចំពោះមុខនៅក្នុងបរិបទកូវីដ-១៩ ស្របតាមផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺឆ្លងកូវីដ១៩ឆ្នាំ២០២១-២០២៥ និងផែនការយុទ្ធសាស្រ្តជាតិអភិវឌ្ឍន៍ទេសចរណ៍២០២១-២០៣៥ ដែលក្រសួងទេសចរណ៍កំពុងរៀបចំ។

## II. ការវិភាគស្ថានភាពទេសចរណ៍

### ១. សភាពការណ៍ទេសចរណ៍កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា មានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដោយឈរលើប្រភព **"បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ"**។ ក្រៅពីតំបន់សៀមរាប-អង្គរ ដ៏មានសក្តានុពលយ៉ាងខ្លាំងផ្នែកទេសចរណ៍វប្បធម៌ប្រវត្តិសាស្រ្ត និងធម្មជាតិ ជាពិសេសភាពល្បីល្បាញនៃតំបន់អង្គរដែលជាបេតិកភណ្ឌរូបីយរបស់មនុស្សជាតិលើពិភពលោក កម្ពុជានៅមានតំបន់សក្តានុពលទេសចរណ៍ជាច្រើនកន្លែងផ្សេងទៀតដូចជា តំបន់ភ្នំពេញ ភូមិភាគឦសាន និងតំបន់ឆ្នេរ ដែលស្ថិតនៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការច្រករបៀងទេសចរណ៍ខាងត្បូង និងជាតារារះនាទិសនិរតីនៃប្រទេសកម្ពុជា។

កម្ពុជាបានអភិវឌ្ឍខ្លួនយ៉ាងឆាប់រហ័ស បានប្រែក្លាយពីប្រទេសដែលមានសង្គ្រាម និងអសន្តិសុខសង្គមកាលពីអតីតកាលមកជា “**ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ**” ជាគោលដៅទេសចរណ៍លំដាប់ពិភពលោក ដែលបានទាក់ទាញទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្តែងក្នុងឆ្នាំ ២០១៩ កម្ពុជាទាក់ទាញបានទេសចរអន្តរជាតិប្រមាណ៦.៦១ លាននាក់មកទស្សនា និងបានបង្កើតឱកាសការងារដោយផ្ទាល់ប្រមាណ៦៣ម៉ឺននាក់ និងរាប់សិបម៉ឺននាក់បន្ថែមទៀតកំពុងតែបម្រើការងារដោយប្រយោល និងបាននាំមកនូវប្រាក់ចំណូលប្រមាណ៤.៩១៩លានដុល្លារអាមេរិក ដោយចូលរួមចំណែកប្រមាណជាង១២,១% នៃផលិតផលសរុបក្នុងស្រុកសរុប(GDP)។

ដោយឡែកក្នុងបរិបទនៃការរីករាលដាលនៃមេរោគឆ្លងកូវីដ-១៩ វិស័យទេសចរណ៍កម្ពុជាទទួលរងផលប៉ះពាល់យ៉ាងទំងន់ ក្នុងនោះឆ្នាំ២០២១ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួន១.៣១លាននាក់ ថយចុះ៨០,២% និងទេសចរជាតិចំនួន ៧.២៣ លាននាក់ ថយចុះ ៣៦,១% ធៀបនឹងឆ្នាំ២០១៩ ដោយបានចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប (GDP) ប្រមាណ ៣%។ ក្នុងបរិបទនេះ ប្រទេសកម្ពុជាទទួលរងផលប៉ះពាល់អវិជ្ជមានជាច្រើនដែលធ្វើឲ្យមានបម្រែបម្រួលហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចតាមរយៈវិស័យគាំទ្រនានា ក្នុងនោះក៏មានវិស័យទេសចរណ៍ផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចុះនូវវិធានការឆ្លើយតបយ៉ាងម៉ឺងមាត់ ដាច់ខាត និងហ្មត់ចត់ក្នុងសមរភូមិចំនួន៣ រួមមាន៖ (១) ការទប់

ស្កាត់មិនឱ្យមានការបន្តនាំជំងឺចូលមកកម្ពុជា **(២)** ការទប់ស្កាត់ការរីករាលដាលជំងឺនៅក្នុងប្រទេស និង**(៣)** ការព្យាបាលអ្នកដែលបានឆ្លងជំងឺកូវីដ-១៩ ព្រមទាំងដាក់ចុះនូវវិធានការគាំទ្រចំនួន ០៧ជុំរួចមកហើយ។

ឆ្នាំ២០២១ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថានឹងមានកំណើនឡើងវិញក្នុងចន្លោះពី២៥% ទៅ ៣៥% តែស្ថិតនៅក្នុងបរិមាណតិចនៅឡើយ ក្នុងនោះចំណូលទេសចរណ៍អន្តរជាតិនឹងទទួលបានប្រមាណ ២ពាន់លានដុល្លា រួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបប្រមាណ៣% មុខរបរ និងការងារក្នុងវិស័យទេសចរណ៍ប្រមាណ៥០ម៉ឺននាក់។ ជាងនេះទៅទៀត នៅឆ្នាំ២០២២ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថានឹងរក្សានូវកំណើនក្នុងចន្លោះពី២០% ទៅ៣០% ។ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំ SEA GAME ឆ្នាំ២០២៣ នេះជាព្រឹត្តិការណ៍ទាក់ទាញទេសចរយ៉ាងខ្លាំងដែលទេសចរអន្តរជាតិត្រូវបានព្យាករណ៍ថានឹងមានកំណើនល្អចន្លោះពី៣០% ទៅ៣៥% ជាបរិមាណតិចនៅឡើយពី ២.៥ ទៅ ៣.៥ លាននាក់។

ដើម្បីធ្វើឲ្យវិស័យទេសចរណ៍កាន់តែមានភាពធន់នឹងវិបត្តិ(Resilient)រាជរដ្ឋាភិបាលបានអនុម័តនូវផែនទីចង្អុលផ្លូវ (Roadmap) ស្ដីពីការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺឆ្លងកូវីដ-១៩ ២០២១–២០២៥ ដែលនឹងក្លាយជាត្រីវិស័យ និងជាផែនការយុទ្ធសាស្ត្រមួយដ៏សំខាន់ដើម្បីធានាដាក់ចេញវិធានការអន្តរាគមន៍ទាន់ពេលវេលាសំដៅប្រែក្លាយវិបត្តិជំងឺឆ្លងកូវីដ-១៩ ឲ្យទៅជាកាលានុវត្តភាពសម្រាប់កែទម្រង់ក្នុងវិស័យទេសចរណ៍កម្ពុជាឲ្យក្លាយជាគោលដៅទេសចរណ៍គុណភាព សុវត្ថិភាព និងនិរន្តរភាព ដោយទាញមកវិញនូវចំនួនភ្ញៀវទេសចរអន្តរជាតិ និងជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក។ ផែនការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍នេះនឹងត្រូវអនុវត្តជា៣ដំណាក់កាលរួមមាន៖ (១) ដំណាក់កាលទី១ (Resilience & Restart)៖ ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី (New Normal) និងរៀបចំផែនការសម្រាប់ស្ដារឡើងវិញ(២០២១) (២) ដំណាក់កាលទី២ (Recovery)៖ ការស្ដារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺឆ្លងកូវីដ-១៩ (២០២២-២០២៣) និង (៣) ដំណាក់កាលទី៣ (Relaunch)៖ ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា(២០២៤-២០២៥)។ ក្រៅពីនេះការអនុម័តផែនការ *មេ* អភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ មានគោលដៅធ្វើឲ្យខេត្តសៀមរាបអាចក្ដាប់យកមកវិញនូវមោទនភាពជាគោលដៅទេសចរណ៍ចំបងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេលមធ្យម និងរយៈវែងនាពេលខាងមុខ។ បន្ថែមពីនេះទៅទៀត ការរៀបចំនូវផែនការ *មេ* អភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី និងខេត្តកែប ក៏ជាយុទ្ធសាស្ត្រគាំទ្រផ្នែកគោលនយោបាយបន្ថែមទៀតដើម្បីចូលរួមស្ដារវិស័យទេសចរណ៍ឡើងវិញចាប់ពីឆ្នាំ២០២១តទៅ គោលបំណងដើម្បីទាញមកវិញជាជំហាននៃទេសចរអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បានប្រកាសជាផ្លូវការពីគម្រោងបើកទទួលទេសចរអន្តរជាតិបានចាក់វ៉ាក់សាំងបង្ការជំងឺឆ្លងកូវីដ-១៩ ( Vaccinated Tourists ) មកទស្សនាគោលដៅទេសចរណ៍សៀមរាប-អង្គរ នៅត្រីមាសទី៤ ឆ្នាំ២០២១។

វិស័យទេសចរណ៍កម្ពុជាត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយដើរតួជា **«មាសបៃតង»** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការការពារបរិស្ថាន ពោលគឺចូលរួមដល់ការកសាងសេដ្ឋកិច្ចបៃតងនៅកម្ពុជា ជាផ្នែកគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ២០១៦-២០៣០ របស់អង្គការសហប្រជាជាតិ ។

បរិបទនេះ វិស័យទេសចរណ៍កម្ពុជាត្រូវបានគេព្យាករណ៍ថាមាន ៣ សេណារីយ៉ូ៖ (១)សេណារីយ៉ូទី១ ថយចុះពី៥០%ទៅ៦០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ២,៥លាននាក់ (២)សេណារីយ៉ូទី២ ថយចុះពី៦០%ទៅ ៧០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ២.០លាននាក់ (៣)សេណារីយ៉ូទី៣ ថយចុះពី៧០%ទៅ៨០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ១,៥ លាននាក់ប៉ុណ្ណោះ។ ស្ថិតក្នុងស្ថានភាពមិនច្បាស់នៃការរីករាលដាលកូវីដ១៩ កម្ពុជាប្រហែលជាស្ថិតនៅក្នុងសេណារីយ៉ូទី៣ដែលផលប៉ះពាល់នៃវិបត្តិកូវីដ-១៩មានដូចជា៖ (១)ខាតបង់ចំណូលទេសចរអន្តរ-ជាតិប្រមាណ៣ពាន់លានដុល្លា (២) រួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប(GDP)អាចថយចុះពីជាង១២%មកក្រោម១០%(៣)មូលដ្ឋានអាជីវកម្មទេសចរណ៍៣,១៣៥ទីតាំង ត្រូវបានបិទ និងផ្អាកដំណើរការ (គិតត្រឹមខែកក្កដា ឆ្នាំ២០២០) រួមមានសណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន ម៉ាស្សា ស្ប៉ា ទីភ្នាក់ងារទេសចរណ៍ កីឡាទេសចរណ៍ និងអាជីវកម្មខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀរហ្គាដិន បុគ្គលិកបម្រើការប្រមាណជាង១១ម៉ឺននាក់ ប្រហែលពី១៥% ទៅ២០% នៃកម្លាំងពលកម្មបម្រើការក្នុងវិស័យទេសចរណ៍ត្រូវបានបញ្ឈប់ការងារក្នុងនោះបុគ្គលិកបម្រើផ្នែកសេវាកម្មរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដូចជាម៉ាស្សា ស្ប៉ា ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាដិន។ ផ្នែកសេវាកម្មស្នាក់នៅដែលផ្តោតលើទីផ្សារទេសចរអន្តរជាតិ ដោយឡែកមគ្គុទ្ទេសក៏ទេសចរម្រមាណជាង៣% ត្រូវបានព្យួរអាជ្ញាបណ្ណទេសចរណ៍។

## ២. សភាពការណ៍ទេសចរណ៍ខេត្តក្រចេះ

ក្នុងរយៈពេលប្រមាណ៥ឆ្នាំចុងក្រោយនេះ តំបន់សក្តានុពលទេសចរណ៍ជាច្រើនកន្លែងក្នុងខេត្តក្រចេះត្រូវបាននិងកំពុងធ្វើការអភិវឌ្ឍ និងសិក្សាស្រាវជ្រាវដើម្បីរៀបចំជាតំបន់ទេសចរណ៍ថ្មីៗទៀត។ បច្ចុប្បន្ន ដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលខេត្តបាន និងកំពុងអភិវឌ្ឍនូវហេដ្ឋារចនា-សម្ព័ន្ធទេសចរណ៍ ការរៀបចំអភិវឌ្ឍក្រុង តំបន់ជុំវិញក្រុង ការរៀបចំសម្បទាទ្រទ្រង់ និងការជំរុញការវិនិយោគនានារួមទាំងការវិនិយោគក្នុងវិស័យទេសចរណ៍ដែរ។

សក្តានុពលសត្វផ្សោតទន្លេមេគង្គ ភាពស្រស់ត្រកាល និងភាពសំបូរបែបនៃធនធានធម្មជាតិដែលជាប្រភពសក្តានុពលទេសចរណ៍ធម្មជាតិបានទាក់ទាញភ្ញៀវទេសចរមកកម្សាន្ត សម្រាកលំហែកាយ និងចង់ដឹងចង់ស្គាល់តំបន់ដែលមានទេសភាពល្អស្អាតក្នុងខេត្តនេះ។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបានអភិវឌ្ឍការធានាបានសុខសន្តិភាព សុវត្ថិភាព ដល់ទេសចរព្រមទាំងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងទេសចរណ៍ និងខេត្តផ្ទាល់ជាមួយការចូលរួមពីគ្រប់មជ្ឈដ្ឋានលើការអនុវត្តប្រពន្ធ័ផ្សព្វផ្សាយ កម្ពុជា ព្រះរាជាណាចក្រអច្ឆរិ-យៈ និងចលនាប្រលងប្រណាំង “ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ” ផងនោះ ខេត្តក្រចេះត្រូវបាន **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត** កំណត់យកវិស័យទេសចរណ៍ជាវិស័យអាទិ-ភាពមួយក្នុងចំណោមវិស័យសំខាន់ៗរបស់ខេត្ត ដែលមានកំណើនគួរឲ្យកត់សំគាល់នាកាលមុនបរិបទកូវីដ-១៩នេះ។

**តារាងទី១ ស្ថិតិសូចនាករទេសចរណ៍ឆ្នាំ ២០១៦-២០២០**

| បរិយាយ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ (ព្យាករណ៍) |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | នាក់ | ២៤,៣៥០ | ២៤,៩៤៧ | ២៥,៩៩០ | ២៦,៨៧៨ | ៥,៣៨០ |
| ទេសចរជាតិ | នាក់ | ៦៧,៦៦៩ | ៧០,១៩៤ | ៧១,៦៣៦ | ៧៤,៤០៥ | ៥៥,៨០០ |
| សេវាស្នាក់នៅ | បន្ទប់ | ៩០៦ | ៨៨២ | ១,០២២ | ១,០៥៦ | ៩,០៧៥ |
| កម្លាំងពលកម្ម | នាក់ | ៥៥៣ | ៥៦៩ | ៥៩០ | ៥៩៨ | ៤១០ |
| ចំណូលទេសចរណ៍ | លាន(៛) | ១៤,៦៤០ | ១៥,១១២ | ១៥,៥៥០ | ១៦,១២៣ | ៣,២២៨ |

**ប្រភព: មន្ទីរទេសចរណ៍ខេត្តក្រចេះឆ្នាំ២០២០**

វិស័យទេសចរណ៍ខេត្តក្រចេះបានរួមចំណែកយ៉ាងសកម្មក្នុងការចូលរួមអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចខេត្ត និងចូលរួមដោយផ្ទាល់ដល់ប្រជាពលរដ្ឋដែលរស់នៅតាមសហគមន៍ទេសចរណ៍ តំបន់រមណីយដ្ឋានទេសចរណ៍ តាមរយៈការផ្តល់ឱកាសការងារ និងមុខរបរ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។ ជាមួយនឹងកំណើនឆាប់រហ័សនៃលំហូរទេសចរមកកាន់ខេត្តក្រចេះ យើងសង្កេតឃើញមានការរីកចម្រើនជាបន្តបន្ទាប់នូវសម្បទាទេសចរណ៍ក្នុងខេត្ត ក្នុងនោះមានរមណីយដ្ឋានទេសចរណ៍សំខាន់ៗចំនួន១៨កន្លែង គឺរមណីយដ្ឋានធម្មជាតិចំនួន១៣កន្លែង រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ៥កន្លែង សណ្ឋាគារមានចំនួន១៤កន្លែង(៦០១បន្ទប់)ផ្ទះសំណាក់ចំនួន៤៨កន្លែង (៤៥០បន្ទប់) ភោជនីយដ្ឋាន និងអាហារដ្ឋានចំនួន៥៨កន្លែង ម៉ាស្សាសុខភាពចំនួន៩កន្លែង មាន (៦៦គ្រែ) សេវាកម្មកម្សាន្តសម្រាប់មនុស្សពេញវ័យចំនួន១៨កន្លែង (៩៦បន្ទប់)។

ជាក់ស្តែងសម្រាប់ឆ្នាំ២០១៩កន្លងទៅ ភ្ញៀវដែលមកលេងកម្សាន្តក្នុងខេត្តក្រចេះសរុបរួមទាំងភ្ញៀវជាតិ និងអន្តរជាតិមានចំនួន១០១,២៨៣នាក់ ប្រៀបធៀបរយៈពេលដូចគ្នាឆ្នាំ២០១៨កើនឡើងចំនួន៣,៦៥៧នាក់ស្មើនឹងប្រមាណ៤% ក្នុងនោះទេសចរអន្តរជាតិមានចំនួន២៦,៨៧៨នាក់ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨កើនឡើងចំនួន៨៨៨នាក់ ស្មើនឹង៣,៥% និងទេសចរជាតិមានចំនួន៧.៤,៤០៥នាក់ ប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨កើនឡើងចំនួន២,៧៦៩នាក់ ស្មើនឹងប្រមាណ៤ %។

សម្រាប់ឆ្នាំ២០២០ តាមការព្យាករណ៍ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបអាចធ្លាក់ចុះមកត្រឹមចំនួន៥,៣៨០នាក់បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩មានការថយចុះចំនួនប្រមាណ៨០%ទេសចរជាតិមានការធ្លាក់ចុះមកត្រឹមចំនួន៥៥,៨០០នាក់ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ មានការថយចុះប្រមាណ២៥ %។

តាមការសិក្សានាឆ្នាំកន្លងមកបង្ហាញឱ្យឃើញថា ខេត្តក្រចេះគឺជាខេត្តមួយដែលភ្ញៀវធ្វើដំណើរឆ្លងកាត់ និងស្នាក់នៅលំហែផងដែរ ចាប់ពីឆ្នាំ២០១៦រហូតមកដល់ឆ្នាំ២០១៩ ភ្ញៀវទេសចរធ្វើដំណើរកម្សាន្តមានការកើនឡើងគួរឱ្យកត់សំគាល់ក្នុងអត្រាកំណើនប្រមាណ១០%និងបានស្នាក់នៅមិនតិចជាង២យប់ ៣ថ្ងៃ ហើយក៏មានភ្ញៀវប្រមាណ៨០%ជាភ្ញៀវរបស់ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវជាលក្ខណៈគ្រួសារ និងឯកជន

ឆ្លងកាត់ និងទស្សនាតែតំបន់ដែលពួកគេចាប់អារម្មណ៍ដូចជាសហគមន៍អេកូទេសចរណ៍កោះទ្រង់ជាដើម តែរយៈពេល១ម៉ោងទៅ៣ម៉ោង និងមួយចំនួនប្រមាណ២%នៃភ្ញៀវមកកម្សាន្តលើកោះផ្សេងៗទៀត រួចបន្តដំណើរទៅកាន់ខេត្តផ្សេងទៀត ភ្ញៀវចំនួន៥%ក្រៅពីនេះបានទៅកម្សាន្តនៅតំបន់អេកូទេសចរណ៍ដែលគេស្នាក់នៅគិតជាមធ្យមប្រមាណ២យប់នៅទីនោះ ដើម្បីទស្សនាសហគមន៍នេសាទ ជនជាតិភាគតិច និងកសិទេសចរណ៍ជាដើម។ គិតជាមធ្យមទេសចរបរទេសម្នាក់ចំណាយត្រឹមតែ២៤០,០០០រៀល ហើយភ្ញៀវជាតិចំណាយក្នុង១នាក់ប្រមាណជា ១៣០,០០០ រៀល។

**ក្រាហ្វិកទី១ ៖** ភ្ញៀវទេសចរទស្សនាខេត្តក្រចេះ ២០១៦ - ២០២០




## ៣. ស្ថានភាពភូមិសាស្ត្រខេត្តក្រចេះ

### ៣.១ ប្រវត្តិខេត្តក្រចេះ

ខេត្តក្រចេះជាដែនដីប្រវត្តិសាស្ត្រតាំងពីសម័យចេនឡា គឺស្រុកសំបូរ ជាអតីតចេនឡាទឹកលិច។ ខេត្តក្រចេះក្លាយពីពាក្យ ក្រចេះ ដែលជាភាសាជនជាតិភាគតិចយោងតាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ភាគទី១ និងភាគទី២ ទំព័រ៩៣០បោះពុម្ពឆ្នាំ១៩៦៧ ខេត្តក្រចេះជាពាក្យជនជាតិស្ទៀង មានន័យថាកំពង់ចម្លងក្របី ដោយសារខេត្តក្រចេះមានជនជាតិភាគតិចភាគច្រើនរស់នៅទីនោះ ហើយការទាក់ទងពាណិជ្ជកម្មផ្សេងៗនៅភូមិភាគឦសានគឺធ្វើនៅតាមច្រកកំពង់ចម្លងក្របីរបស់ជនជាតិស្ទៀងដែលឆ្លងពីក្រចេះទៅតំបន់ខាងលើមកតំបន់ខាងក្រោម ព្រមទាំងមកផ្លាស់ប្តូរទំនិញទៅវិញទៅមកគឺនៅកំពង់ចម្លងមួយនេះឯង ដោយនាសម័យកាលក្រុងសម្ពុបុរៈ ស្តេចលាវតែងតែនាំសួយសារអាករមកថ្វាយស្តេចខ្មែរតាមរយៈកំពង់ចម្លងនេះដែរ។

### ៣.២ ភូមិសាស្ត្រទូទៅខេត្តក្រចេះ

ខេត្តក្រចេះមានផ្ទៃដី១១.០៩៤ គ.ម២ ស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជាមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តមណ្ឌលគីរី ខាងលិចជាប់នឹងខេត្តកំពង់ធំ ខាងជើងជាប់នឹងខេត្តស្ទឹងត្រែង ខាងត្បូងជាប់នឹងខេត្តត្បូងឃ្មុំ កំពង់ចាម និងស្រុកឡុកនិញ ខេត្តបិញភឿករបស់ប្រទេសវៀតណាម ដែលមានព្រំប្រទល់លាតសន្ធឹងប្រវែង ៧៤.៥គីឡូម៉ែត្រ ។

ទន្លេមេគង្គមានប្រភពពីភ្នំទីបេត៍ហូរកាត់ខេត្តក្រចេះចំងាយ១៤០គ.ម នាំមកជាមួយនូវដីល្បាប់ដែលមានជីជាតិដល់ស្រែចម្ការ អំណោយផលដល់កសិកម្ម ដែលជាប្រភពដ៏សំខាន់របស់ប្រជាពលរដ្ឋរស់នៅតាមតំបន់ដងទន្លេ។ ខេត្តក្រចេះចែកចេញជាក្រុង១ ស្រុក៥ មាន៤២ឃុំ ៥សង្កាត់ស្មើនឹង២៥៨ភូមិ។ ប្រជាពលរដ្ឋភាគច្រើន (៧0%) រស់នៅតាមដងទន្លេ និង(៣0%)រស់នៅតាមតំបន់ព្រៃភ្នំ ដែលក្នុងនោះ៨% ជាជនជាតិដើមភាគតិច ដែលរួមមានចំនួន៧ជនជាតិគឺៈ ព្នង គួយ ក្រោល មិល ខោញ ស្ទៀង និងថ្មូន។

ខេត្តក្រចេះត្រូវបានលើកសសើរពីមរតកវប្បធម៌ ប្រវត្តិរឿងព្រេងពីសម័យបុរាណ និងសម្រស់ធម្មជាតិរបស់ខ្លួនមិនដាច់ពីមាត់។ ស្រុកសំបូរជាអតីតរាជធានីពីសម័យចេនឡា និងវត្តវិហារសសរ១០០ ពីសតវត្សទី១៦ ដែលទាក់ទងនឹងរឿងព្រេងនិទានក្រពើនេនធនរបស់ខ្មែរបុរាណ។ មរតកវប្បធម៌ទាំងនេះបានបន្សល់ទុកនូវប្រាសាទបុរាណមួយចំនួនពីសតវត្សទី៨ ដូចជាប្រសាទខ្ទាន់ពីរ ប្រាសាទប្រាំ ប្រាសាទកោះគ្រៀងដែលមានទេវរូបស្រីគ្រប់លក្ខណ៍ វិហារបុរាណ ផ្ទះខ្មែរបុរាណ(ផ្ទះសសរ១០០ នៅស្រុកឆ្លូងជាដើម ដែលបច្ចុប្បន្ននេះ ផ្ទះបុរាណនោះត្រូវបានរុះរើគ្រឿងឈើទាំងអស់យកមកកសាងឡើងវិញនៅបរិវេណវត្តវិហារកាកណ្តាល)រហូតដល់អគាររចនាបថសល់ពីសម័យអាណានិគមបារាំង។

តំបន់ព្រៃភ្នំធំធេង ជួរភ្នំប្រាំពាន់ ទន្លេមេគង្គប្រកបដោយកោះតូចធំរាប់រយ ទឹកជ្រូរ ទឹកធ្លាក់ អន្លង់ផ្សោត អន្លង់ត្រី សត្វក្តាន់កម្រជិតផុតពូជ សត្វស្លាប និងសត្វអណ្តើកកម្រ ព្រមទាំងឆ្នេរខ្សាច់សស្អាត ដែលត្រូវបានរាជរដ្ឋាភិបាលកំណត់តំបន់ទាំងនោះជាដែនជម្រកសត្វព្រៃព្រែកប្រសព្វ និងស្រុកសំបូរ កាលពីខែតុលា ឆ្នាំ២០១៨ កន្លងទៅនេះ។ ក្រៅពីធនធានធម្មជាតិផ្តល់នូវទស្សនីយភាពទាក់ទាញសម្រាប់ទេសចរ ក៏នៅមានវប្បធម៌ជនជាតិដើមភាគតិច ទំនៀមទំលាប់ ការរស់នៅ ជីវភាពប្រជាជនតាមដងទន្លេមេគង្គលើ ក៏ផ្តល់នូវឱកាសពិសេសសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍ផងដែរ។

ផ្លូវគោកផ្លូវជាតិលេខ៧ ភ្នំពេញ-ក្រចេះចម្ងាយ ៣៤០គ.ម ជាផ្លូវចាក់កៅស៊ូធំស្អាតមានលក្ខណៈអន្តរជាតិដែលអាចបម្រើឲ្យការដឹកជញ្ជូនផ្លូវគោក និងការធ្វើដំណើររបស់ភ្ញៀវជាតិនិងអន្តរជាតិ។ តាមផ្លូវជាតិលេខ៧ និងផ្លូវខេត្តលេខ៧៣ដែលមានចម្ងាយសរុប២៥០គ.ម គឺជិតជាងផ្លូវជាតិលេខ៧ ដល់ទៅ៩០គ.ម។ ពេលភ្ញៀវធ្វើដំណើរពីកំពង់ចាមតាមផ្លូវជាតិលេខ៧បាន៣៦គ.ម រថយន្តត្រូវបត់ឆ្វេងមកតាមផ្លូវខេត្តលេខ៧៣ដែលជាប្រភេទផ្លូវចាក់កៅស៊ូប្រវែង៩០គ.ម ឆ្លងកាត់ស្រុកតំបែរ ស្រុកឆ្លូងរួចបន្តមកដល់ទីរួមខេត្តក្រចេះតែម្តង ។

ទេសចរអាចធ្វើដំណើរតាមរថយន្តធុនតូច និងតាមម៉ូតូតាមផ្លូវមាត់ទន្លេពីកំពង់ចាម មកក្រចេះតាមផ្លូវមាត់ទន្លេរហូតដល់ទីប្រជុំជនស្ទឹងត្រង់ រួចឆ្លងស្ពានមកត្រើយខាងកើត បន្តដំណើរតាមផ្លូវមាត់ទន្លេ

កាត់ស្រុកក្រូចឆ្មារ និងស្រុកឆ្លូងមកកាន់ទីរួមខេត្តក្រចេះ។ ចម្ងាយសរុបគឺ២៤១គ.ម ពីភ្នំពេញ (ភ្នំពេញ-កំពង់ចាម ១៤១ គ.ម កំពង់ចាម-ក្រចេះ ១១៧ គ.ម) ។

ផ្លូវជាតិលេខ៧៖ ក្រចេះ-ស្ទឹងត្រែង (១៤១ គ.ម) រួចបន្តរហូតដល់ព្រំដែនកម្ពុជា-ឡាវ ដែលជាផ្លូវអន្តរជាតិស្ថាបនាឡើងដោយក្រុមហ៊ុនស៊ាងហៃរបស់ប្រទេសចិន។ ផ្លូវក្រចេះ-មណ្ឌលគិរី (២១៥ គ.ម)មានកំណាត់ផ្លូវពីស្នួលទៅដល់ក្រុងសែនមនោរម្យ១៣២គ.ម ជាប្រភេទផ្លូវក្រាលកៅស៊ូ។ សេវាដឹកអ្នកដំណើរកាន់តែប្រសើរឡើងដោយមានរថយន្តឈ្នួលសេរីទំនើបៗប្រកបដោយផាសុកភាព ដឹកជញ្ជូនភ្ញៀវជារៀងរាល់ថ្ងៃ ពីភ្នំពេញ - ក្រចេះ និងពីក្រចេះ - ភ្នំពេញ។

សម្រាប់ផ្លូវទឹកភ្នំពេញ-ក្រចេះចម្ងាយ២២០គ.ម អាចធ្វើដំណើរទាំងប្រាំង និងទាំងវស្សា។ ប៉ុន្តែសព្វថ្ងៃនេះ ពុំមានក្រុមហ៊ុនណាធ្វើអាជីវកម្មនោះទេ ដោយសោហ៊ុយធ្វើដំណើរតាមកាណូតលឿន(ភ្នំពេញ-ក្រចេះ) ចំណាយខ្ពស់ជាងតាមរថយន្ត។ សព្វថ្ងៃទាំងភ្ញៀវជាតិ និងអន្តរជាតិងាកមកធ្វើដំណើរតាមផ្លូវគោកវិញ ។

ចំពោះវិស័យទេសចរណ៍ខេត្តក្រចេះ មានការអភិវឌ្ឍរីកចម្រើនគួរជាទីមោទនៈដែលបម្រើភ្ញៀវទេសចរជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋឲ្យមកលេងកម្សាន្តសប្បាយ ហើយបានទាញយកកំលាំងពលកម្មដោយផ្ទាល់សរុបប្រមាណ៦៩៣នាក់/ស្រី៤៨៥នាក់ នាឆ្នាំ២០១៩ (ដោយមិនរាប់បញ្ចូលកំលាំងពលកម្មនៅតាមសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍)។ ដោយមានការយកចិត្តទុកដាក់ពីអាជ្ញាធរក្នុងការថែទាំការពារ និងកែលម្អផលិតផលសេវាកម្មទេសចរណ៍នៅក្នុងខេត្តជាបន្តបន្ទាប់ដើម្បីឲ្យមានសោភណ្ឌភាពមានភាពទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលមកកាន់តែច្រើនឡើងៗ ដែលក្នុងនោះរួមមានរមណីយដ្ឋានអន្លង់ផ្សោតកាំពីដែលមានផ្សោតទន្លេមេគង្គដែលសកលលោកសព្វថ្ងៃចាប់អារម្មណ៍ជាខ្លាំង និងបានទទួលស្គាល់ជាសត្វមានដោយកម្រផងដែរ។

## ៤. សម្បទា និងសេវាកម្មទេសចរណ៍ខេត្តក្រចេះ

### ៤.១ ផលិតផល និងការទាក់ទាញទេសចរណ៍

បច្ចុប្បន្ននេះចំនួនភ្ញៀវទេសចរដែលមកទស្សនានៅតំបន់សក្តានុពលមានការកើនឡើង ដែលធ្វើឲ្យភ្ញៀវទេសចរបង្កើនការស្នាក់នៅកម្ពុជា និងបង្វែរទិសដៅពីការទស្សនាខេត្តដែលមានតំបន់ទេសចរណ៍សក្តានុពលខ្ពស់មកទស្សនាតំបន់ធម្មជាតិក្នុងខេត្តក្រចេះ និងមួយចំនួនទៀតតាមរយៈក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍នានាដែលគេពង្រីកកញ្ចប់ធ្វើដំណើរកម្សាន្តរបស់ក្រុមហ៊ុនទាំងនោះតាមផ្លូវគោក និងតាមដងទន្លេមេគង្គ។ ចំនួនភ្ញៀវទេសចរនេះនឹងអាចថយចុះទៅវិញប្រសិនបើមិនមានការអភិវឌ្ឍតំបន់កម្សាន្តថ្មីៗបន្ថែម និងម៉្យាងទៀតបើតំបន់ធម្មជាតិត្រូវបានបំផ្លិចបំផ្លាញ ខ្វះការអភិរក្សព្រមជាមួយខ្វះកិច្ចសហការជាមួយផ្នែកឯកជន ឬពីសហគមន៍ណាមួយដែលអាចចូលរួមច្នៃបង្កើតផលិតផលទាក់ទាញទេសចរក្រៅតែពីផលិតផលដែលមានស្រាប់ដែលមិនអាចរួមចំណែកបង្កើនកំណើនទេសចរបានគ្រប់គ្រាន់ឡើយ។

កត្តាជាមូលដ្ឋានសំខាន់ចាំបាច់បំផុតនោះក្នុងការទាក់ទាញភ្ញៀវទេសចរនោះ គឺការអភិវឌ្ឍផលិតផលទេសចរណ៍ ហើយការអភិវឌ្ឍផលិតផលទាំងអស់នោះគឺត្រូវផ្តោតលើការធ្វើពិពិធកម្មផលិតផល ធ្វើឲ្យមាន

លក្ខណៈថ្មីប្លែកពីគេ(Unique) ដែលអាចស្របតាមទីផ្សារបច្ចុប្បន្ន និងលើកកម្ពស់ផលិតផលដែលមានស្រាប់ប្រកបដោយស្តង់ដារនិងមានគុណភាពខ្ពស់។ ការអភិវឌ្ឍផលិតផលទេសចរណ៍មានទាំងផ្នែករឹង និងផ្នែកទន់ ផ្តោតជាសំខាន់លើសម្បត្តិធនធានធម្មជាតិប្រភពសក្តានុពលនានារបស់ខេត្តសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់ ។

ការអភិវឌ្ឍវិស័យទេសចរណ៍តាមតំបន់អាទិភាពគឺជាការចាំបាច់មួយ ហើយត្រូវតែកំណត់ទៅតាមប្រភេទផលិតផលទេសចរណ៍ដោយធ្វើការសិក្សា និងវាយតម្លៃឲ្យបានលម្អិតច្បាស់លាស់ទៅលើប្រភពធនធានសក្តានុពលទាក់ទាញផ្នែកទេសចរណ៍ ផលប៉ះពាល់ផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ ជាគោលការណ៍និងទស្សនៈទាន់រួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ពិតជាមានភាពចាំបាច់ណាស់ដែលក្នុងនោះរួមមានដូចជារាជរដ្ឋាភិបាល ផ្នែកឯកជន និងសមាគមអង្គការមិនមែនរដ្ឋាភិបាលជាដើម។

**តារាងទី២** រមណីយដ្ឋានទេសចរណ៍ខេត្តក្រចេះ ឆ្នាំ២០២០

| ល.រ | ឈ្មោះរមណីយដ្ឋានទេសចរណ៍ | ឈ្មោះឡាតាំង | ចម្ងាយ |
|---|---|---|---|
| **១. រមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្រ្ត** | | | |
| ១ | រមណីយដ្ឋានវត្តសសរ១០០ | 100 pillars pagoda | ៣៦ |
| ២ | រមណីយដ្ឋានភ្នំសំបុក | Phnom Sambok | ១០ |
| ៣ | រមណីយដ្ឋានវត្តវិហារបុរាណរកាកណ្តាល | Roka Kandal Pagoda Temple | ២ |
| ៤ | រមណីយដ្ឋានភ្នំសុពណ៌កាឡី | Phnom Sopor Kaley | ៤៥ |
| ៥ | រមណីយដ្ឋានប្រាសាទប្រាំ | Bram Temple | ១៨ |
| **២. រមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងសហគមន៍ទេសចរណ៍** | | | |
| ១ | រមណីយដ្ឋានអន្លង់ផ្សោត | Dolphin Pool | ១៥ |
| ២ | រមណីយដ្ឋានទឹកជ្ជរកាំពី | Kampi Rapid water | ១៦ |
| ៣ | រមណីយដ្ឋានភ្នំព្រះ | Phnom Preah | ៣៥ |
| ៤ | រមណីយដ្ឋានតាព្រហ្ម | Ta Prom | ៦៥ |
| ៥ | សហគមន៍អេកូទេសចរណ៍កោះទ្រង់ | CBET Koh Trong | ១ |
| ៦ | សហគមន៍អេកូទេសចរណ៍ព្រែកជ្រៃមាំង | CBET Prek Crey Mang | ៩៥ |
| ៧ | សហគមន៍អេកូទេសចរណ៍កោះសាមសិប | CBET Koh Sam Seb | ៩៥ |
| ៨ | សហគមន៍អេកូទេសចរណ៍កោះផ្តៅ | CBET Koh Pdao | ៤៣ |
| ៩ | សហគមន៍អេកូទេសចរណ៍កោះដំបង | CBET Koh Dam Bang | ៩៨ |

| | | | |
|---|---|---|---|
| ១០ | សហគមន៍អេកូទេសចរណ៍កោះព្រហ្មចារីយ៍ជ្រោយបន្ទាយ | CBET Koh Proma Charey Chroy Ban Teay | ១៧ |
| **៣. រមណីយដ្ឋានកែច្នៃ** | | | |
| ១ | រមណីយដ្ឋានកោះសុក្រម | Koh So Krorm Resort | ១២ |
| ២ | រមណីយដ្ឋានទំនប់ជីវឺន៧៩ | Chi Vern 79 Resort | ៩៤ |
| ៣ | រមណីយដ្ឋានឆ្នេរសុពណ៌កាឡី | Sopor Kaley River Beach | ៤៧ |
| **៤. សិប្បកម្មកែច្នៃបម្រើឲ្យវិស័យទេសចរណ៍** | | | |
| ១ | សហគមន៍ក្រឡានថ្មគ្រែ | **Kro Lan Thmor Kre( Stick Rice Cake)** | ១៥ |

**ប្រភព: មន្ទីរទេសចរណ៍ខេត្តក្រចេះ**

ក្រោយពីបានសិក្សាយ៉ាងល្អិតល្អន់ពីភូមិសាស្ត្រនៃខេត្តក្រចេះរួចមក យើងអាចបែងចែកតំបន់សក្តានុពលទេសចរណ៍ធំៗជាពតំបន់សំខាន់រួមមានដូចជា៖

១.តំបន់សក្តានុពលទេសចរណ៍ក្នុងក្រុង និងទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ

២.តំបន់សក្តានុពលទេសចរណ៍មេគង្គលើនៃតំបន់ធម្មជាតិ និងសហគមន៍ទេសចរណ៍

៣.តំបន់សក្តានុពលកសិទេសចរណ៍តាមដងទន្លេមេគង្គ។

ដោយមានការយកចិត្តទុកដាក់ចង្អុលណែនាំពីក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្តក្រចេះផ្ទាល់ក្នុងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងយុទ្ធនាការផ្សព្វផ្សាយ" កម្ពុជាព្រះរាជាណាចក្រអច្ឆរិយ: ផ្តល់ភាពកក់ក្តៅ" នោះ មន្ទីរទេសចរណ៍ខេត្តបានសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះពង្រឹងគុណភាពសេវាកម្មដែលមានស្រាប់ និងបានបង្កើតផលិតផលទេសចរណ៍ថ្មី ប្រកបដោយគុណភាពបន្ថែមទៀតជូនភ្ញៀវទេសចរគួបផ្សំនឹងកត្តាសន្តិសុខសណ្តាប់ធ្នាប់សង្គមធ្វើឱ្យទេសចរជាតិនិងអន្តរជាតិមកទស្សនាខេត្តក្រចេះពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានភាពទាក់ទាញគួរឲ្យកត់សម្គាល់។

## ៤.២ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

**តារាងទី៣ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ខេត្តក្រចេះ ឆ្នាំ២០១៦-២០២០**

| **បរិយាយ** | **ឯកតា** | **២០១៦** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** |
|---|---|---|---|---|---|---|
| សណ្ឋាគារ | បន្ទប់ | ៥៨៦ | ៥៦២ | ៦២១ | ៦២១ | ៦២១ |
| ផ្ទះសំណាក់ | បន្ទប់ | ៣២០ | ៣២០ | ៤៥០ | ៤៥០ | ៤៥០ |
| ភោជនីយដ្ឋាន | កៅអី | ១៦០០ | ១៧០០ | ១៨៥០ | ២១៨៩ | ២១៨៩ |
| ទូកដឹកភ្ញៀវ | ទូក | ២៥ | ២៥ | ២៥ | ២៦ | ២៧ |

| មគ្គុទ្ទេសក៍ទេសចរណ៍តំបន់ | នាក់ | ៩ | ១៣ | ១៦ | ១៦ | ១៦ |
|---|---|---|---|---|---|---|

ប្រភព: មន្ទីរទេសចរណ៍ខេត្តក្រចេះ ឆ្នាំ២០២០

## ៤.៣ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍

ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលកម្ពុជា ការពង្រឹងសមត្ថភាព និងការថែរក្សាវប្បធម៌ប្រពៃណីរបស់ប្រជាជនដែលក្នុងនោះការអភិវឌ្ឍជំនាញក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។ ជាងនេះទៅទៀតចំនួនអ្នកលក់វត្ថុអនុស្សាវរីយ៍ក្នុងខេត្តក្រចេះមានតិចហើយភាគច្រើនលក់នៅក្នុងបណ្ណាគារ តាមទីផ្សារ តាមផ្ទះផ្ទាល់ខ្លួន និងមួយចំនួនទៀតលក់នៅតាមបណ្តារមណីយដ្ឋានភាគច្រើនជារបស់ច្នៃពីធនធានធម្មជាតិមានស្រាប់ក្នុងស្រុក។ តាមរយៈគំហើញនេះ មន្ទីរទេសចរណ៍ខេត្តបានធ្វើការផ្សព្វផ្សាយដោយសម្របសម្រួលឲ្យអាជីវករចូលរួមក្នុងការលើកស្ទួយសិល្បៈខ្មែរដែលកើតចេញពីស្នាដៃកូនខ្មែរ វត្ថុអនុស្សាវរីយ៍ដែលមានដូចជា គំនូរ គ្រឿងចម្លាក់ធ្វើពីថ្ម ត្បូងថ្ម ឈើ និងសម្ភារៈប្រើប្រាស់ដែលធ្វើពីសូត្រ ក្រមា ត្នោត ដូង ផ្តៅ ឫស្សីជាដើម ។

បច្ចុប្បន្ននេះនៅក្នុងខេត្តក្រចេះមានហាងលក់វត្ថុអនុស្សាវរីយ៍ចំនួន ២៤កន្លែងគឺៈ

**តារាងទី៤ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍**

| ទីតាំង | ឈ្មោះហាងលក់វត្ថុអនុស្សាវរីយ៍ | ប្រភេទវត្ថុអនុស្សាវរីយ៍ |
|---|---|---|
| ក្រុងក្រចេះ | ១. ពណ្ណារាយ<br>២. ជ័យសម្បត្តិ<br>៣. ត្រាយមុំ<br>៤. អ៊ី លីលី<br>៥. ទូច ដានី<br>៦. អាដាក្រចេះ<br>៧. ហោ ស៊ីណាល់<br>៨. ហ៊ារ ប៊ុន្នី | ឈើ |
| ស្រុកចិត្របុរី | ១. ធឿន ស៊ីថា<br>២. អ៊ុង វ៉ាន្នី<br>៣. ទុយ សុផាណា<br>៤. ចរណៃ<br>៥. អ៊ុក ផានិត | ឈើ |

| | | |
|---|---|---|
| | ៦. ឈ្នាង ម៉ាស៊ីន<br>៧. ទីវ សារ៉ាត់<br>៨. ឌុក ម៉ៅ<br>៩. ឌុក ផា<br>១០. ម៉ៅ ម៉ៃ<br>១១. ស្រី អន<br>១២. គិន សុខេន<br>១៣. ថេង សុភ័ណ្ឌ<br>១៤. ថោង ស្រី<br>១៥. ទុយ សុវណ្ណសិលា<br>១៦. នៃ សារុំ | |

ប្រភព: មន្ទីរទេសចរណ៍ខេត្តក្រចេះ

## ៥. ការវិភាគចំណុចខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង

ការវិភាគSWOTនេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីស្ថានភាពទេសចរណ៍ក្នុងខេត្ត(បច្ចុប្បន្ន និងអនាគត)។ លទ្ធផលនៃការវិភាគSWOTនេះ នឹងអាចជួយកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ឲ្យកាន់តែមានភាពច្បាស់លាស់ប្រកបដោយប្រសិទ្ធិភាព និងភាពទទួលខុសត្រូវខ្ពស់ ដែលបង្ហាញឲ្យឃើញពីសក្តានុពលទេសចរណ៍ក្នុងខេត្តក្រចេះដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកលើកិត្យានុភាពមុខមាត់ខេត្តតាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍។ កត្តាសន្តិសុខ និងសុវត្ថិភាពល្អ ក៏ជាចំណុចសំខាន់មួយដែរសម្រាប់ទាក់ទាញទេសចរមកកម្សាន្តនៅក្នុងខេត្តនេះ។

លើសពីនេះទៅទៀត ការវិភាគក៏នឹងបង្ហាញថាខេត្តផ្តល់ឱកាសច្រើនជូនអ្នកវិនិយោគលើវិស័យទេសចរណ៍ដោយមានកិច្ចការគាំទ្រផ្សេងៗ។

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្ត ជាពិសេសផ្លូវធ្វើដំណើរតភ្ជាប់តំបន់ភ្នំពេញមកក្រចេះដោយកាត់តាមស្រុកតំបែរ និងឆ្លងដោយមានស្ពានទើបសាងសង់ថ្មីធ្វើពីបេតុងអាចឲ្យរថយន្តទេសចរណ៍តូច ធំ ឆ្លងកាត់បានងាយស្រួលព្រមទាំងចំណាយពេលលឿនរហ័ស ក្រចេះតភ្ជាប់ទៅកាន់ខេត្តសៀមរាបកាត់តាមកំពង់ធំដោយមានស្ពានឆ្លងកាត់ទន្លេ | - ការអភិវឌ្ឍផលិតផល និងសេវាកម្មទេសចរណ៍នៅតំបន់រមណីយដ្ឋានទេសចរណ៍នានាពុំទាន់បានរៀបចំឲ្យបានល្អប្រសើរនៅឡើយ<br>- ការវិនិយោគទុនរបស់ផ្នែកឯកជននៅមានកម្រិត<br>- ការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ពុំទាន់មានភាពទូលំទូលាយ |

| | |
|---|---|
| - មានសក្តានុពលទេសចរណ៍សម្រាប់ការអភិវឌ្ឍទេសចរណ៍ទាំងផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ ធម្មជាតិ តំបន់កែច្នៃ<br>- មានសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពល្អ<br>- ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធពីគ្រប់ខេត្តគោលដៅ<br>- ទីតាំងខេត្តស្ថិតនៅតាមដងទន្លេមេគង្គដែលចំងាយប្រមាណជា១៤០គ.ម | - សេវាកម្មទេសចរណ៍មិនគ្រប់គ្រាន់ នៅមិនទាន់ស្របតាមស្តង់ដា<br>- កង្វះខាតធនធានមនុស្សក្នុងវិស័យទេសចរណ៍ទាំងផ្នែកឯកជន និងស្ថាប័នសាធារណៈ<br>- មិនទាន់មានការសហការលើវិស័យទេសចរណ៍ពីគ្រប់ភាគីពាក់ព័ន្ធឲ្យបានល្អប្រសើរ<br>- ពុំទាន់មានដៃគូអភិវឌ្ឍន៍លើផ្នែកទេសចរណ៍<br>- ការរៀបចំព្រឹត្តិការណ៍សម្រាប់ទាក់ទាញទេសចរនៅមានកម្រិត។ |
| **ឱកាស** | **ការគំរាមកំហែង** |
| - ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីរមណីយដ្ឋានមួយទៅកាន់រមណីដ្ឋានមួយមានស្ថានភាពល្អប្រសើរដែលជាឱកាសសម្រាប់ទាក់ទាញភ្ញៀវទេសចរ មកកាន់ខេត្តក្រចេះ<br>- រមណីយដ្ឋានទេសចរណ៍នៅមានច្រើនសម្រាប់ធ្វើការអភិវឌ្ឍដើម្បីទាក់ទាញភ្ញៀវទេសចរ និងបង្កើតឱកាសការងារជូនប្រជាជនក្នុងតំបន់<br>- ធនធានសក្តានុពលទេសចរណ៍ជាច្រើននៅមិនទាន់បានកែច្នៃនិងការប្រើប្រាស់ក្នុងគោលដៅទេសចរណ៍ឲ្យបានអស់លទ្ធភាពនៅឡើយ | - ការរីករាលដាលនៃមេរោគកូវីដ១៩ ដែលពុំទាន់អាចផ្តល់ភាពច្បាស់លាស់<br>- មិនទាន់មានការគ្រប់គ្រងកាកសំណល់ឲ្យបានល្អ<br>- ការបាត់បង់ធនធានធម្មជាតិ សត្វផ្សោតទន្លេមេគង្គរងផលប៉ះពាល់ដោយមានការប្រែប្រួលអាកាសធាតុ<br>- សំណង់អគារប្រវត្តិសាស្ត្រមួយចំនួនមានភាពចាស់ទ្រុឌទ្រោមទាមទារឲ្យមានផែនការរៀបចំស្តារ កែលម្អ |

ជាលទ្ធផលការវិភាគSWOTបានបង្ហាញថាខេត្តក្រចេះជាខេត្តមួយដែលមានប្រភពសក្តានុពល ដើរតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកលើការកំណត់ពីកិត្យានុភាព មុខមាត់ខេត្ត តាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍។ ការវិភាគនេះក៏បានបង្ហាញផងដែរថាសក្តានុពលធនធានមិនទាន់បានយកមកប្រើប្រាស់ឲ្យអស់លទ្ធភាពនៅឡើយ ដូច្នេះ ខេត្តនេះនឹងមានឱកាសខ្ពស់ក្នុងការទាក់ទាញអ្នកវិនិយោគមកអភិវឌ្ឍក្នុងតំបន់ទេសចរណ៍របស់ខេត្ត។

ទន្ទឹមនឹងនេះ ក៏នូវមានបញ្ហាគំរាមកំហែងនិងចំណុចខ្សោយមួយចំនួនដែលត្រូវធ្វើការរួមគ្នាដើម្បីស្វែងរកយុទ្ធសាស្ត្រ វិធីសាស្ត្រ ក្នុងការរៀបចំអភិវឌ្ឍឲ្យបានប្រសើរ និងសម្រេចឲ្យបានដល់គោលដៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍របស់ខេត្តក្រចេះនាពេលបច្ចុប្បន្ន និងពេលអនាគត។

## III. ចក្ខុវិស័យ

ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍ និងរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសជាតិទទួលបាននូវសុខសន្តិភាព ស្ថេរភាព សម្បូរសប្បាយរុងរឿង ជីវភាពរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរ។ ក្នុងរយៈពេលជាង ១០ឆ្នាំកន្លងមកនេះ យើងមើលឃើញពីលំហូររបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកម្សាន្តតាមតំបន់រមណីយដ្ឋានទេសចរណ៍នានាតាមបណ្តាខេត្តមានការកើនឡើងជារៀងរាល់ឆ្នាំ។ ដោយមើលឃើញពីចំនុចទាំងអស់ខាងលើនេះ ការជំរុញលើកស្ទួយការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះ ជាយន្តការមួយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ ខេត្តក្រចេះ ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះមានចក្ខុវិស័យ៖ ***ខេត្តក្រចេះនឹងក្លាយទៅជាខេត្តគោលដៅឋានសួគ៌នៃទេសចរណ៍ធម្មជាតិ វប្បធម៌ ព្រមទាំងជាខេត្តគំរូមានភាពទាក់ទាញជាងគេនៅក្នុងតំបន់ភូមិភាគឦសានតាមរយៈការពង្រឹងគុណភាពផលិតផលទេសចរណ៍ឲ្យកាន់តែមានគុណភាព មានបង្កើតនូវព្រឹត្តិការណ៍ទេសចរណ៍ប្លែកថ្មីៗ ដើម្បីទាក់ទាញភ្ញៀវទេសចរចូលមកកម្សាន្តក្នុងខេត្តក្រចេះឲ្យកាន់តែកើនទ្វេរដង។***

## IV. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ

ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ ខេត្តក្រចេះជាឯកសារដ៏មានសារៈសំខាន់សម្រាប់តម្រង់ទិសដៅក្នុងការអភិវឌ្ឍទេសចរណ៍ខេត្តប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងការទទួលខុសត្រូវខ្ពស់។ ដើម្បីសម្រេចបានគោលដៅនេះ សៀវភៅផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម៥ឆ្នាំរបស់មន្ទីរទេសចរណ៍ខេត្តក្រចេះដល់ត្រឹមឆ្នាំ២០២៥ មានគោលបំណង និងទិសដៅអភិវឌ្ឍដូចខាងក្រោម៖

### ១. គោលបំណង

ធនធានឧស្សាហកម្ម និងសេវាកម្មទេសចរណ៍ក្នុងខេត្តក្រចេះ នឹងត្រូវបានអភិវឌ្ឍ និងកែលម្អប្រកបដោយគុណភាពដោយមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ដើម្បីស្រូបយកបានទេសចរជាតិ និងអន្តរជាតិមកទស្សនាខេត្តក្រចេះកើនទ្វេរដងត្រឹមឆ្នាំ២០២៥ ព្រមជាមួយនឹងការកម្សាន្ត និងស្នាក់នៅប្រកបដោយការពេញចិត្ត ចំណាយពេលយ៉ាងតិចពីរយប់។

សៀវភៅផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តក្រចេះ មានគោលបំណង និងទិសដៅអភិវឌ្ឍដូចខាងក្រោម៖

១. បង្កើនផលិតផលទេសចរណ៍ថ្មីៗ ប្លែកៗ ប្រកបដោយគុណភាពដើម្បីផ្គត់ផ្គង់ទីផ្សារទេស-ចរណ៍ កសិទេសចរណ៍ ដោយប្រែក្លាយពីកសិដ្ឋានចម្ការហូបផ្លែទៅជាទីកន្លែងកម្សាន្តផ្តល់

បទពិសោធន៍ ចំពោះវិស័យកសិកម្មនឹងប្រែក្លាយតំបន់ទាក់ទាញធម្មជាតិដែលមានសក្តានុពលផ្សារភ្ជាប់នឹងសហគមន៍ឲ្យក្លាយជាតំបន់អេកូទេសចរណ៍

២. កែលម្អរមណីយដ្ឋានទេសចរណ៍ និងសហគមន៍ទេសចរណ៍ដែលមានស្រាប់ដោយតម្រង់ទិសស្របបទដ្ឋាននៃចលនាប្រឡងប្រណាំងរមណីយដ្ឋាន និងសហគមន៍ទេសចរណ៍គំរូ

៣. លើកទឹកចិត្តចំពោះសហគមន៍ ឬវិស័យឯកជនក្នុងការវិនិយោគបង្កើតកន្លែងកម្សាន្តទាំងកែច្នៃ និងធម្មជាតិឲ្យបានច្រើនបន្ថែមទៀតសម្រាប់បម្រើការកម្សាន្តរបស់ភ្ញៀវទេសចររួមចំណែកបង្កើនការងារជូនប្រជាពលរដ្ឋ បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ

៤. ជំរុញវិស័យទេសចរណ៍របស់ខេត្តឲ្យក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការអភិរក្សធនធានធម្មជាតិ និងធនធានវប្បធម៌មូលដ្ឋានជាគោលដៅទាក់ទាញបំផុត

៥. អភិវឌ្ឍទេសចរណ៍ខេត្តក្រចេះទៅជាគោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ធម្មជាតិ និងកែច្នៃប្រកបដោយភាពទាក់ទាញ និងមាននិរន្តរភាពដើម្បីទាក់ទាញទេសចរជាតិអាចមកទស្សនាកំសាន្តបានចំនួន១៧០,០០០ម៉ឺននាក់ និងទេសចរអន្តរជាតិចំនួនប្រហែល ១៧,០០០ នាក់ឆ្នាំ២០២៥ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្តក្រចេះ។

## ២. គោលដៅ

ដើម្បីសម្រេចគោលដៅអភិវឌ្ឍវិស័យទេសចរណ៍ទាមទារឲ្យមានការចូលរួមសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសសាមីមន្ទីរទេសចរណ៍ខេត្តផ្ទាល់ត្រូវយកចិត្តទុកដាក់ជាចម្បងទៅលើគុណភាពធនធានមនុស្ស ដោយពង្រឹងបំប៉នសមត្ថភាព សិក្សាចំណេះដឹងថ្មីៗប្រកបដោយគុណភាព និងគុណធម៌ដល់មន្ត្រីបុគ្គលិកក្នុងអង្គភាពដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់សម្រេចឲ្យបាននូវគោលបំណង និងទិសដៅខាងលើ។

**ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តក្រចេះ មានគោលដៅដូចខាងក្រោម៖**

១. ធ្វើឱ្យប្រសើរឡើងនូវតំបន់ទេសចរណ៍ធម្មជាតិវប្បធម៌ចាស់ថ្មីនៅក្នុងខេត្តដើម្បីស្រូបយកភ្ញៀវទេសចរជាតិនិងអន្តរជាតិឲ្យមកទស្សនាខេត្តក្រចេះកាន់តែច្រើន និងស្នាក់នៅបានយូរ

២. ការអនុវត្តបទដ្ឋានគតិយុត្ត និងច្បាប់សម្រាប់ឧស្សាហកម្មនិងសេវាកម្មទេសចរណ៍ហើយក៏ត្រូវបានអនុវត្តនិងរៀបចំបានយ៉ាងល្អប្រសើរដើម្បីជាប្រភពបង្កើតប្រាក់ចំណូលនិងការងារក្នុងវិស័យទេសចរណ៍ដោយផ្ទាល់ និងប្រយោលសម្រាប់សហគមន៍និងភាគីពាក់ពន្ធ័ផ្សេងៗ

៣. លើកកម្ពស់កិត្យានុភាពខេត្ត និងរួមចំណែកកសាងសេដ្ឋកិច្ច សង្គម បង្កើតការងារជូនប្រជាពលរដ្ឋក្នុងតំបន់ឲ្យបានច្រើន និងចូលរួមលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋឲ្យជៀសផុតពីភាពក្រីក្រ

៤. ផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍របស់ខេត្តដើម្បីទាក់ទាញអ្នកវិនិយោគដៃគូពាក់ព័ន្ធនានា ដើម្បីចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់

៥. បង្កើតឱកាសការងារ និងបង្កើនប្រាក់ចំណូលបន្ថែមតាមរយៈវិស័យទេសចរណ៍ដោយផ្ទាល់ និងប្រយោលឲ្យបានជាអតិបរមាក្នុងរយៈពេល៥ឆ្នាំខាងមុខ (២០២១-២០២៥)

៦. ផ្សព្វផ្សាយ និងជំរុញលើកទឹកចិត្តឲ្យប្រជាជនក្នុងមូលដ្ឋានបានចូលរួមក្នុងការថែរក្សា ការពារ សម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងបរិស្ថាន

៧. រួមចំណែកអនុវត្តគោលនយោបាយជាតិលើវិស័យទេសចរណ៍ និងបទដ្ឋានគតិយុត្តនានា របស់អាជ្ញាធរខេត្ត និងក្រសួងទេសចរណ៍។

ដើម្បីធានាសម្រេចបានដល់គោលដៅខាងលើនេះ ជាចាំបាច់តម្រូវឲ្យមានធនធានគ្រប់គ្រាន់ ទាំងធនធានមនុស្ស និងថវិកា។ លើសពីនេះទៅទៀតការចូលរួម និងកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ អង្គការក្នុងស្រុក ក្រៅរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋានផ្ទាល់ក្នុងការរៀបចំអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍៥ឆ្នាំខេត្តក្រចេះនេះ។

## V. ក្របខ័ណ្ឌអភិវឌ្ឍន៍ទេសចរណ៍

### ១. ការវិភាគការអភិវឌ្ឍទេសចរណ៍

ទោះបីជាខេត្តក្រចេះមានសក្តានុពលយ៉ាងសំបូរបែបក៏ដោយចំពោះការអភិវឌ្ឍវិស័យទេសចរណ៍ ចំនួនភ្ញៀវទេសចរមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ក៏ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តភាពនៅក្នុងខេត្តក្រចេះនៅតែមានជួបឧបសគ្គនិងបញ្ហាប្រឈមមួយចំនួននាពេលបច្ចុប្បន្ននេះដែលតម្រូវឲ្យមានការពិនិត្យឆ្លុះបញ្ចាំង និងមានការដោះស្រាយជាជំហានៗដែរ។

### ១.១ ការអភិវឌ្ឍផលិតផលទេសចរណ៍

ការអភិវឌ្ឍផលិតផលទេសចរណ៍ផ្តោតសំខាន់ផលិតផលទេសចរណ៍ថ្មីៗ ការបង្កើតរមណីយដ្ឋាន និងសេវាកម្មទេសចរណ៍ជាដើម។ ការអភិវឌ្ឍទេសចរណ៍អាចធ្វើទៅបានអាស្រ័យទៅលើកត្តា២សំខាន់គឺ តម្លៃសេវាកម្ម និងធនធានមនុស្ស។ ការកំណត់តម្លៃកញ្ចប់សេវាកម្មទេសចរណ៍ ជាការប្រកួតប្រជែងនឹងបណ្តាខេត្តជិតខាងជាចំណុចដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែមឲ្យមកទស្សនាខេត្តក្រចេះ។ ការរៀបចំសេវាកម្មល្អ មានគុណភាពសម្រាប់បំរើដល់ភ្ញៀវទេសចរវាក៏ជាយុទ្ធសាស្ត្រមួយដែរក្នុងការប្រមូលគៀងគរនូវរាល់ប្រភេទភ្ញៀវទេសចរទាំងអស់មកកាន់តំបន់នៃខេត្តក្រចេះនេះទាំងមូល ។

ការរៀបចំបរិស្ថានស្អាត ការគ្រប់គ្រងកាកសំណល់ ការផ្គត់ផ្គង់ប្រពន្ធ័ទឹកស្អាត ថាមពលអគ្គិសនីគ្រប់-គ្រាន់ ហេដ្ឋារចនាសម្ពន្ធ័ខ្នាតតូចដូចជាបង្គន់អនាម័យសាធារណៈ និងតាមតំបន់រមណីយដ្ឋានទេសចរណ៍ជាចលករមួយជំរុញដល់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព។ ក្នុងន័យនេះបើការជំរុញការអភិវឌ្ឍសម្បទាទេសចរណ៍មានលក្ខណៈយឺតយ៉ាវនោះ វាជាកត្តាអាចទទួលរងនូវផលអវិជ្ជមាននៃលំហូរភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្តក្រចេះដែរ ។

លើសពីនេះទៅទៀតនោះ ការអភិវឌ្ឍធនធានមនុស្សលើជំនាញទេសចរណ៍នៅក្នុងខេត្តក្រចេះពិតជារួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍ខេត្តមួយនេះប្រកបដោយភាពរីកចម្រើន និងឆ្លើយតបតាមតម្រូវការទីផ្សារបច្ចុប្បន្ននេះ។ ការជួយគាំទ្រដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងរយៈពេលវែងពីបណ្តាដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងការជំរុញឲ្យមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ប្រចាំតំបន់ក៏គួរត្រូវបានលើកទឹកចិត្តខ្ពស់ជានិច្ច។

## ១.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

តាមការសិក្សាបានបង្ហាញថាការសិក្សាទីផ្សារបានលម្អិត និងច្បាស់លាស់ពីតម្រូវការភ្ញៀវទេសចរ និងការផ្សព្វផ្សាយអោយបានទូលំទូលាយជាផ្នែកមួយជួយជំរុញកំណើនភ្ញៀវទេសចរយ៉ាងឆាប់រហ័ស។ កង្វះខាតរបស់អង្គភាពជំនាញក្នុងការស្រាវជ្រាវឲ្យបានស៊ីជម្រៅពីទីផ្សារទេសចរណ៍ ការកំណត់ប្រភេទទេសចរ និងផ្សព្វផ្សាយផលិតផលទេសចរណ៍នៅមានកម្រិត ហើយម៉្យាងទៀតផលិតផលទេសចរណ៍នៅក្នុងខេត្តក៏ពុំមានលក្ខណៈប្លែក គុណភាពនៅពុំទាន់គ្រប់គ្រាន់តាមស្តង់ដាត្រឹមត្រូវវាជាកត្តាធ្វើឲ្យជះឥទ្ធិពលដល់កំណើនទេសចរពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត។ ការចូលរួមរបស់វិស័យឯកជនក្នុងការផ្សព្វផ្សាយផលិតផលទេសចរណ៍នៅពុំទាន់ស៊ីសង្វាក់គ្នាដោយផ្សព្វផ្សាយដាច់ដោយឡែកពីគ្នា សម្ភារៈផ្សព្វផ្សាយទេសចរណ៍ទាំងនោះទាំងគុណភាព និងបរិមាណនៅមានកម្រិត ផ្សព្វផ្សាយពុំទាន់បានចំគោលដៅ ហើយប្រព័ន្ធបច្ចេកទេសក៏ជាបញ្ហាតម្រូវឲ្យអ្នកអនុវត្តត្រូវរិះរកយុទ្ធសាស្ត្រដោះស្រាយជាជំហានៗដែរ។

## ១.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

ចំពោះហេដ្ឋារចនាសម្ព័ន្ធផ្លូវតភ្ជាប់ទៅកាន់តំបន់រមណីយដ្ឋានទាក់ទាញទេសចរមួយចំនួននៅតែជាបញ្ហាប្រឈមក្នុងការសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវ។ ការជំរុញឲ្យមានការអភិវឌ្ឍឲ្យបានឆាប់រហ័សនូវបណ្តាញផ្លូវមួយចំនួនទៀតក៏ជាការប្រសើរដល់ការស្រូបយកភ្ញៀវទេសចរបន្ថែមទៀតមកកម្សាន្ត និងស្នាក់នៅឲ្យបានយូរនៅក្នុងខេត្តដ៏មានសក្តានុពលមួយប្រចាំតំបន់ភាគឦសាននៃប្រទេសកម្ពុជានេះ។ គម្រោងការសាងសង់ស្ពានថ្មីដែលតភ្ជាប់ពីខេត្តក្រចេះទៅកាន់ខេត្តកំពង់ធំ សៀមរាប និងផែនការសាងសង់កំពង់ផែទេសចរណ៍ទន្លេមេគង្គ ជាសករាជថ្មីមួយទៀតក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះ និងតំបន់នៅជុំវិញដើម្បីស្រូបទាញយកទេសចរបន្ថែមទៀត។

ដោយឡែកការរៀបចំឲ្យបើកចរាចរណ៍យ៉ាងទូលំទូលាយតាមផ្លូវគោកដោយឆ្លងកាត់តាមច្រកទ្វារអន្តរជាតិត្រពាំងស្រែនូវលំហូរទេសចរដែលជ្រើសរើសការធ្វើដំណើរឆ្លងកាត់តាមច្រកនេះ ជាចំណុចមួយដ៏ប្រសើរដល់កំណើនភ្ញៀវទេសចរមកកាន់ខេត្តក្រចេះ តែក៏តម្រូវឲ្យមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវផលិតផលទេសចរណ៍ក្នុងខេត្តរបស់ខ្លួនដោយការរៀបចំឲ្យមានចំណតភ្ញៀវទេសចរ និងមណ្ឌលព័ត៌មានទេសចរណ៍សម្រាប់ផ្តល់ព័ត៌មានដល់ទេសចរឲ្យបានកាន់តែប្រសើរក្នុងពេលអនាគតដ៏ខ្លីនេះ ។

## ១.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

នាពេលបច្ចុប្បន្ននេះទោះបីជាខេត្តក្រចេះ ពុំទាន់មានចោទជាបញ្ហាធ្ងន់ធ្ងរចំពោះសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរដោយសារតែលំហូរទេសចរនៅមានចំនួនតិចមកកាន់ខេត្តក្រចេះក៏ដោយ ប៉ុន្តែនាពេលអនាគត នៅពេលកំណើនភ្ញៀវទេសចរកាន់តែច្រើននោះភាពប្រថុយប្រថាន ផលអវិជ្ជមានគឺកាន់តែខ្ពស់។ ការវិភាគជាយុទ្ធសាស្ត្រលើការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរនឹងបង្ហាញឲ្យយើងដឹងកាន់តែច្បាស់នូវបញ្ហាដែលអាចកើតមានឡើងចំពោះទេសចរ ដូចជាបញ្ហាកេងបន្លំពីជនខិលខូចមួយចំនួនលក់ផលិតផលក្លែងក្លាយដើម្បីបោកប្រាស់ទេសចរ ភាពអនាធិបតេយ្យរបស់អ្នកនាំភ្ញៀវ និងសេវាកម្មដឹកជញ្ជូនយកតម្លៃហួសកម្រិត អនាម័យម្ហូបអាហារ ការស្នាក់នៅ និងបញ្ហាគ្រោះថ្នាក់ជាយថាហេតុផ្សេងៗជាដើម គឺតម្រូវឲ្យយើងប្រុងប្រយ័ត្នទុកជាមុនដើម្បីធានាបានសន្តិសុខ សុវត្ថិភាព និងសុខដុមរមនារបស់ភ្ញៀវ ដើម្បីជួយដល់ការលើកមុខមាត់ជូនខេត្តក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ហើយស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

បញ្ហាប្រឈមមួយចំនួនពីបញ្ហាសុវត្ថិភាពរបស់ភ្ញៀវ ដែលភាពអសកម្មនេះទាមទារឲ្យមានការខិតខំប្រឹងប្រែងពីគ្រប់ភាគីពាក់ព័ន្ធរួមមាន៖

- អនាម័យចំណីអាហារមិនទាន់បានល្អជាទូទៅ ពិសេសនៅតាមតំបន់កម្សាន្ត អាហារចម្អិនស្រាប់តាមអាហារដ្ឋានតាមបណ្ដោយផ្លូវជាតិ
- មណ្ឌលកម្សាន្តសម្រាប់មនុស្សពេញវ័យមួយចំនួនបានជ្រកក្រោមស្លាកទេសចរណ៍ ប្រព្រឹត្តអំពើពេស្យាកម្ម និងគ្រឿងញៀនដែលធ្វើឲ្យប៉ះពាល់ដល់ប្រពៃណី និងវប្បធម៌ដ៏ល្អរបស់សង្គមជាតិ
- ការកំណត់គោលដៅទេសចរណ៍ក្នុងតំបន់អេកូទេសចរណ៍នៅមិនទាន់មានភាពជាក់លាក់ ជាពិសេសក្នុងតំបន់អភិរក្សធម្មជាតិដូចជាទីតាំងទស្សនាសត្វព្រៃ ទីតាំងដំណើរផ្សងព្រេង ទីតាំងសម្រាកបោះតង់ក្នុងព្រៃ។ល។ ដែលជាបញ្ហាប្រឈមចំពោះសុវត្ថិភាពទេសចរ
- បន្តពង្រឹងការអនុវត្តនូវវិធានសុវត្ថិភាពដើម្បីទប់ស្កាត់ជំងឺកូវីដ១៩។

## ១.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង

ផែនការសកម្មភាពដោយមានកិច្ចសហការអនុវត្តជាមួយស្ថាប័នពាក់ព័ន្ធរួមមានសមត្ថកិច្ច និងអង្គភាពនានាក្នុងការដោះស្រាយការប្រឈមចំពោះបណ្ដាប្រតិបត្តិករទេសចរណ៍មួយចំនួនដែលធ្វើអាជីវកម្មបម្រើឲ្យវិស័យទេសចរណ៍ទាំងមិនទាន់មានច្បាប់អនុញ្ញាតពីស្ថាប័នជំនាញ មិនទាន់មានវិញ្ញាបនបត្របញ្ជាក់ពីការបណ្ដុះបណ្ដាលបដិសណ្ឋារកិច្ច ការមិនសហការ ឬគេចវេសកាតព្វកិច្ចដែលត្រូវបំពេញ ជាហេតុប៉ះពាល់ដល់គុណភាពសេវាទេសចរណ៍ សុវត្ថិភាពភ្ញៀវ និងការបង្កភាពអសកម្មផ្សេងៗទៀតកើតចេញពីភ្ញៀវទេសចរជ្រកក្រោមស្លាកគ្រឿងញៀន និងឧក្រិដ្ឋកម្មជាដើម។

## ១.៦ ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សក្នុងមុខជំនាញទេសចរណ៍នៅមានកម្រិត តម្រូវការធនធានមនុស្សដែលមានវិជ្ជាជីវៈច្បាស់លាស់ពិតប្រាកដ ប្រកបដោយបទពិសោធន៍ដើម្បីបំរើឲ្យវិស័យទេសចរណ៍ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះមានភាពរីកចម្រើន និងឆ្លើយតបតាមតម្រូវការទីផ្សារបច្ចុប្បន្ននេះកំពុងជាឧបសគ្គ និងចោទជាបញ្ហាខ្លាំង។ ការជួយគាំទ្រដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងរយៈពេលវែងពីបណ្តាដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងការជំរុញឲ្យមាននូវសាលាបណ្តុះ-បណ្តាលវិជ្ជាជីវៈទេសចរណ៍ប្រចាំតំបន់គឺត្រូវបានលើកទឹកចិត្ត។

បញ្ហាប្រឈមមួយចំនួនដែលតែងតែជួបប្រទះនៅក្នុងការអនុវត្តផែនការសម្រាប់ការអភិវឌ្ឍធនធានមនុស្សរួមមាន ៖

- តួនាទីជំនាញរបស់មន្ត្រីមន្ទីរពុំទាន់បានឆ្លើយតបបានតាមសំណូមពរការងារដែលកំពុងឈានឡើង
- សមត្ថភាពមន្ត្រីមួយចំនួនមានកម្រិតវប្បធម៌ខ្ពស់ប៉ុន្តែនៅខ្វះបទពិសោធន៍ក្នុងការងារ
- ធនធានមនុស្សក្នុងបណ្តាសេវាកម្មឯកជន និងសហគមន៍នៅមានភាពទន់ខ្សោយក្នុងការចាប់យកការយល់ដឹងឲ្យស៊ីជម្រៅពីវិស័យទេសចរណ៍
- បណ្តាមូលដ្ឋានសេវាកម្មឯកជន ជារួមនៅមិនទាន់បានស៊ីជម្រៅពីសមភាពយេនឌ័រក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ពិសេសស្ត្រីបម្រើឲ្យទី-តាំងអាជីវកម្មកម្សាន្ត រីឯមូលដ្ឋានអាជីវកម្មខ្លះទៀតនៅមិនទាន់មានតំណាងស្ត្រីសម្រាប់អង្គភាពរបស់ខ្លួននៅឡើយទេ
- ការអភិវឌ្ឍធនធានមនុស្សក្នុងមុខជំនាញទេសចរណ៍នៅមានកម្រិត តម្រូវការធនធានមនុស្សដែលមានវិជ្ជាជីវៈពិតប្រាកដ និងមានបទពិសោធន៍ដើម្បីបំរើឲ្យវិស័យទេសចរណ៍ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះប្រកបដោយភាពរីកចម្រើន និងឆ្លើយតបតាមតម្រូវការទីផ្សារបច្ចុប្បន្ននេះកំពុងជាឧបសគ្គ និងចោទជាបញ្ហាខ្លាំង។

## ១.៧ ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍

ជាយុទ្ធសាស្ត្រ ដើម្បីជំរុញកំណើនភ្ញៀវទេសចរទាំងភ្ញៀវជាតិ និងអន្តរជាតិ ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗបន្ថែមដែលជាការធ្វើពិពិធកម្មផលិតផលទេសចរណ៍ក្នុងតំបន់ត្រូវតែធ្វើការជំរុញ និងមានការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាព។ ខេត្តក្រចេះមានឱកាសច្រើនក្នុងការជំរុញ និងទាក់ទាញវិនិយោគិនដើម្បីធ្វើការវិនិយោគលើវិស័យឧស្សាហកម្មទេសចរណ៍បន្ថែមក្នុងតំបន់។ ខេត្តក្រចេះជាខេត្តមួយក្នុងភូមិភាគឦសាន ដែលចាត់ទុកជាតំបន់ទេសចរណ៍ធម្មជាតិសំបូរដោយធនធានធម្មជាតិជាច្រើនរួមមានតំបន់អន្លង់ផ្សោតកាំពី ទឹកជ្រូរទន្លេមេគង្គកាំពី ភ្នំ ជ្រូរភ្នំ និងជាពិសេសតំបន់ដែលមានសក្តានុពលខ្ពស់តាមដងទន្លេមេគង្គសំបូរដោយធនធាន និងជីវចម្រុះគ្រប់ប្រភេទ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះកំណើនភ្ញៀវទេសចរទាំងភ្ញៀវជាតិ និងអន្តរជាតិ មានការកើនឡើងគួរជាទីមោទនៈ ហើយការជំរុញបង្កើតបន្ថែមនូវសម្បទាទេសចរណ៍ក្នុងតំបន់ជាការចាំបាច់បំផុតសម្រាប់បម្រើដល់វិស័យទេសចរណ៍ក្នុងខេត្ត ។

## ១.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

ដោយមើលឃើញពីទិសដៅរយៈពេលវែង ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិត្រូវគិតគូរដល់ការងារគ្រប់គ្រង និងអភិរក្សធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។ ធនធានជាច្រើនត្រូវបានមើលឃើញថាកំពុងទទួលរងការបំផ្លិចបំផ្លាញដោយសារការគ្រប់គ្រងពុំមានប្រសិទ្ធភាព ។

ធនធានដែលជាលក្ខណៈទោលដូចជាផ្សោតទន្លេមេគង្គ ជីវៈចម្រុះគ្រប់ប្រភេទក្នុងអាងទន្លេមេគង្គ និងធនធានធម្មជាតិជាច្រើនទៀត កំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារប្រសិទ្ធភាពក្នុងការគ្រប់គ្រងពុំទាន់មានយន្តការអនុវត្តច្បាស់លាស់។ ការទទួលរងផលប៉ះពាល់ពីការជ្រៀតចូលមកនូវវប្បធម៌ទំនៀមទំលាប់ ប្រពៃណីផ្សេងៗដល់ប្រជាជនមូលដ្ឋានក៏ជាបញ្ហាចោទដែលយើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់លើកិច្ចការពារ ថែរក្សា និងអភិរក្សផងដែរ ។

ការជំរុញដោយមានការទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីស្វែងរកនូវយុទ្ធសាស្ត្ររយៈពេលខ្លី និងវែងក្នុងគោលបំណងរៀបចំយុទ្ធសាស្ត្ររួមដើម្បីគ្រប់គ្រង អភិរក្សធនធានសម្បត្តិវប្បធម៌ ដែលមានស្រាប់ ដូចជា ការលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងតំបន់ ។

លើសពីនេះ នៅមានបញ្ហាប្រឈមមួយចំនួនទៀតផងដែរដូចជាៈ

- កង្វះខាតថវិកាក្នុងការរៀបចំអភិវឌ្ឍទេសចរណ៍ ជាឧបសគ្គមួយរាំងស្ទះដល់ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព
- កង្វះខាតធនធានមនុស្សក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ មន្ត្រីជំនាញមានបទពិសោធន៍សម្រាប់បំរើការងារដល់មន្ទីរទេសចរណ៍
- រមណីយដ្ឋានសហគមន៍ទេសចរណ៍ដែលបានបង្កើតឡើងថ្មីៗងាយស្រួលនឹងបាត់បង់ទៅវិញដោយសារកង្វះខាតថវិកា ធនធានមនុស្ស និងគ្មានជំនាញគ្រប់គ្រងច្បាស់លាស់
- ការចូលរួមរបស់វិស័យឯកជន ដែលបម្រើការក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៅមានកម្រិត និងកង្វះចំណេះ ជំនាញក្នុងការអភិវឌ្ឍលើវិស័យទេសចរណ៍នេះ
- ការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងមន្ទីរទេសចរណ៍ជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួនពុំទាន់ច្បាស់លាស់ ការងារទទួលខុសត្រូវមួយចំនួនត្រួតស៊ីគ្នា
- ការចូលរួមជាមួយស្ថាប័ន មន្ទីរពាក់ពន្ធ័មួយចំនួននៅមានកម្រិត។

## ២. ទិសដៅអភិវឌ្ឍន៍ទេសចរណ៍

ដោយផ្អែកលើមូលដ្ឋានសម្បត្តិវប្បធម៌ ធនធានធម្មជាតិដ៏សំបូរបែប ហើយជាពិសេសវប្បធម៌

ប្រពៃណីរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ការចុះសិក្សាស្រាវជ្រាវព័ត៌មាន និងធ្វើអង្កេត យើងបានកំណត់នូវទិសដៅជាយុទ្ធសាស្រ្ត និងយុទ្ធសាស្រ្តអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះដើម្បីដាក់ចេញនូវផែនការយុទ្ធសាស្រ្តមានលក្ខណៈច្បាស់លាស់ និងប្រសិទ្ធភាពខ្ពស់។ ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងជោគជ័យជាចាំបាច់ត្រូវមានគន្លឹះសំខាន់ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមមានផ្នែករដ្ឋាភិបាល (Publics) ផ្នែកឯកជន (Private) វិនិយោគគិន (Investor) ដៃគូអភិវឌ្ឍន៍ (Development Partner) និងប្រជាពលរដ្ឋ (People) ក្នុងសហគមន៍។ យុទ្ធសាស្រ្តអាទិភាពក្នុងការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះរួមមាន៨ចំណុចសំខាន់ៗៈ

១. ការអភិវឌ្ឍផលិតផលទេសចរណ៍
២. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍
៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍
៤. សន្តិសុខ សុវត្ថិភាព និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន
៥. ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រងវិស័យទេសចរណ៍
៦. ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រ
៧. ការវិនិយោគក្នុងវិស័យទេសចរណ៍
៨. ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

## ២.១ ការអភិវឌ្ឍផលិតផលទេសចរណ៍

ជាមូលដ្ឋានចាំបាច់បំផុតក្នុងការទាក់ទាញទេសចរនោះគឺការអភិវឌ្ឍផលិតផលទេសចរណ៍ ហើយការអភិវឌ្ឍផលិតផលទាំងអស់នោះត្រូវផ្តោតលើការធ្វើពិពិធកម្មផលិតផលដែលមានលក្ខណៈថ្មី ប្លែកពីគេ (Unique) ស្របតាមទីផ្សារបច្ចុប្បន្ន និងលើកកម្ពស់ផលិតផលមានស្រាប់ប្រកបដោយស្តង់ដា និងមានគុណភាពខ្ពស់។ ការអភិវឌ្ឍផលិតផលទេសចរណ៍មានទាំងផ្នែករឹង និងទន់ដោយផ្តោតជាសំខាន់លើសម្បត្តិធនធានធម្មជាតិ ប្រភពសក្តានុពលនានារបស់ខេត្តធ្វើជាមូលដ្ឋានក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់។

ការអភិវឌ្ឍទេសចរណ៍តាមតំបន់អាទិភាពជាការចាំបាច់ ហើយត្រូវកំណត់តាមប្រភេទផលិតផលទេសចរណ៍ដោយធ្វើការសិក្សា វាយតម្លៃ ឲ្យបានលម្អិតច្បាស់លាស់ទៅលើប្រភពធនធានសក្តានុពលទាក់ទាញផ្នែកទេសចរណ៍ ផលប៉ះពាល់ផ្នែកបរិស្ថាន សេដ្ឋកិច្ចសង្គម។ ជាគោលការណ៍ និងទស្សនទានរួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ពិតជាមានភាពចាំបាច់ណាស់ ដែលក្នុងនោះរួមមានរាជរដ្ឋាភិបាល ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាលជាដើម។

### ក. ការធ្វើពិពិធកម្មផលិតផល

នៅក្នុងជំហាននៃការអភិវឌ្ឍផលិតផលទេសចរណ៍ ការធ្វើពិពិធកម្ម និងការលើកកម្ពស់លើគុណភាពសេវាកម្មមានស្រាប់ ការសិក្សាស្រាវជ្រាវបង្កើតផលិតផលថ្មីៗដើម្បីឲ្យសមស្របជាមួយនឹងនិន្នាការតម្រូវការទីផ្សារទេសចរណ៍ពិភពលោក វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ លើសពីនេះទៅទៀតនោះការ

គិតគូរពីផលប្រយោជន៍ និងការចូលរួមរបស់សហគមន៍នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍផលិតផលក៏មានសារៈសំខាន់ផងដែរក្នុងការចូលរួមការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។ ក្នុងការធ្វើពិពិធកម្មផលិតផល និងសេវាកម្មទេសចរណ៍ត្រូវបានកំណត់ជាពីរផ្នែកសំខាន់ៗរួមមាន ការអភិវឌ្ឍផលិតផល និងសេវាកម្មសហគមន៍អេកូទេសចរណ៍ និងការអភិវឌ្ឍផលិតផលនិងសេវាកម្មនៅតាមរមណីយដ្ឋានផ្សេងៗ។

### ក.១. ការបង្កើត និងអភិវឌ្ឍសហគមន៍អេកូទេសចរណ៍

ជាយន្តការនៃការអភិវឌ្ឍទេសចរណ៍ដោយមានការចូលរួម និងការទទួលខុសត្រូវខ្ពស់លើការអភិរក្សធនធានធម្មជាតិ និងវប្បធម៌។ ដូចនេះការកំណត់យកការអភិវឌ្ឍផលិតផលនិងសេវាកម្មក្នុងសហគមន៍អេកូទេសចរណ៍ជាគន្លឹះដ៏សំខាន់ដើម្បីធ្វើឲ្យសម្រេចបាននូវទស្សនវិស័យ មានគោលដៅជាក់លាក់ ដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រខាងលើនេះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅតាមបណ្តាសហគមន៍អេកូទេសចរណ៍ក្នុងខេត្តក្រចេះទាំងអស់រួមមានសហគមន៍អេកូទេសចរណ៍កោះទ្រង់ កោះផ្ដៅ កោះសាមសិបជាដើមនោះនៅមានចំនុចខ្វះខាតមួយចំនួនដែលត្រូវជំរុញបន្ថែមដើម្បីបំពេញនូវតម្រូវការចរន្តទីផ្សារទេសចរណ៍នាពេលបច្ចុប្បន្ននេះ។ ត្រង់ចំនុចនេះ ការអភិវឌ្ឍផលិតផលសហគមន៍អេកូទេសចរណ៍ត្រូវផ្ដោតសំខាន់លើការរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដែលចាំបាច់ដូចជាស្លាកសញ្ញាបង្ហាញទិស និងព័ត៌មានផ្សេងៗ ធុងសំរាម ចំណតរថយន្ត ទោចក្រយានយន្ត និងរានសម្រាកលំហែ។ល។ ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើគោលការណ៍រចនាសម្ព័ន្ធយន្តការផ្សេងៗក្នុងការគ្រប់គ្រងរបស់សហគមន៍អេកូទេសចរណ៍នៅតាមតំបន់នីមួយៗក៏ត្រូវផ្ដោតការយកចិត្តទុកដាក់ផងដែរ។ ការកសាងសមត្ថភាពសមាសភាពគណៈកម្មការគ្រប់គ្រងក៏ត្រូវរំលេចឡើងឲ្យឃើញនៅក្នុងផែនការសកម្មភាពដែលត្រូវអនុវត្ត។

### ក.២. អភិវឌ្ឍផលិតផលទេសចរណ៍នៅតាមតំបន់រមណីយដ្ឋាន

ជាកត្តាចាំបាច់ដែរក្នុងការកែលម្អ និងរៀបចំបន្ថែមទៀតដែលក្នុងនោះរួមមានរមណីយដ្ឋានព្រែកកាំពី ភ្នំសំបុក វិហារសសរ១០០ រមណីយដ្ឋានតាព្រហ្មជាដើម ហើយការអភិវឌ្ឍនេះក៏មានទិសដៅប្រហាក់ប្រហែលនឹងចំនុច(ក.១)ដែរ ដែលផ្ដោតសំខាន់លើការកែសម្រួលរៀបចំរចនាសម្ព័ន្ធ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច រួមទាំងការកសាងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងជាដើម។

## ខ. ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ

ដោយមើលឃើញពីកំណើនទេសចរពិភពលោកមានការកើនឡើងជាលំដាប់ហើយទេសចរដែលបានមកទស្សនាកម្សាន្តខេត្តក្រចេះមានការកើនឡើងផងដែរ។ ដូចនេះធនធាន និងឧស្សាហកម្មទេសចរណ៍ដែលមានស្រាប់ និងបានអភិវឌ្ឍហើយពុំអាចផ្គត់ផ្គង់ទទួលទេសចរឲ្យបានគ្រប់គ្រាន់បានឡើយ។ ការសិក្សាស្រាវជ្រាវអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ប្លែកៗ គឺជាគោលការណ៍គ្រឹះមួយក្នុងការត្រៀមទទួលផ្គត់ផ្គង់ទេសចរមកកម្សាន្តក្នុងខេត្តក្រចេះឲ្យបានគ្រប់គ្រាន់អាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងបាន។

## ខ.១. ធ្វើការសិក្សាស្រាវជ្រាវសក្តានុពលតំបន់ទេសចរណ៍ថ្មីៗ

ទេសចរណ៍ធម្មជាតិ និងវប្បធម៌ដែលបានបង្កប់នៅក្នុងព្រៃ និងដងទន្លេមេគង្គក្នុងខេត្តក្រចេះ ត្រង់ចំណុចនេះការរៀបចំក្រុមការងារស្នូលដើម្បីចុះសិក្សាស្រាវជ្រាវពីធនធានសក្តានុពលទេសចរណ៍ ដែលអាចមានលទ្ធភាពបង្កើតជាតំបន់ទេសចរណ៍រួមទាំងធម្មជាតិ និងប្រពៃណីវប្បធម៌ផ្សេងៗផងដែរ។ កិច្ចសហការសិក្សាជាមួយអង្គការពាក់ព័ន្ធចំពោះការផ្តួចផ្តើមបង្កើត និងអភិវឌ្ឍសហគមន៍អេកូទេសចរណ៍នៅក្នុងតំបន់អភិរក្សសត្វក្ងាន់ និងសត្វស្លាបនៃតំបន់ការពារព្រៃលិចទឹកទន្លេមេគង្គ តំបន់អេកូទេសចរណ៍ទឹកជ្រួរតាចោរក្រហម៩ ស្ថិតក្នុងឃុំកោះខ្ញែរ តំបន់អូរច្រឡង់មានព្រំប្រទល់ជាប់ខេត្តស្ទឹងត្រែងស្ថិតនៅក្នុងឃុំអូរគ្រៀង ស្រុកសំបូរ ប្រាសាទខ្វាន់ពីរនិងតំបន់ជុំវិញស្ថិតក្នុងឃុំថ្មី នៃស្រុកចិត្របុរី និងតំបន់ធម្មជាតិនានាក្នុងខេត្តអំណោយផលមានសក្តានុពល (បឹងធម្មជាតិ តំបន់កសិកម្ម កសិ-ឧស្សាហកម្ម ព្រៃធម្មជាតិដែលមានការថែទាំគាំពារដោយប្រជាសហគមន៍ និងអាជ្ញាធរមានសមត្ថកិច្ច)។

## ខ.២. រៀបចំអភិវឌ្ឍតំបន់ទេសចរណ៍ថ្មីៗ

ក្រោយពីសិក្សាស្វែងរកពីសក្តានុពលនៃធនធានទេសចរណ៍ទាំងអស់នោះបានហើយ ការចាត់ចែងរៀបចំបង្កើតតំបន់ទេសចរណ៍ក៏ត្រូវចាត់ចូលក្នុងសកម្មភាពអាទិភាព។ ការបង្កើតតំបន់ទេសចរណ៍នោះគឺសំដៅលើការបង្កើតទាំងសហគមន៍អេកូទេសចរណ៍ សហគមន៍ទេសចរណ៍ធម្មជាតិ និងរមណីយដ្ឋានកែច្នៃផ្សេងៗទៀតដែលអាចបំពេញឲ្យតម្រូវការទេសចរបាន។ ការចងក្រង និងរៀបចំបង្កើតត្រូវកំណត់លើការរៀបចំនីតិវិធី យន្តការគ្រប់គ្រង និងផែនការកសាងសមត្ថភាពសម្រាប់គណៈកម្មការគ្រប់គ្រង។

លើសពីនេះទៅទៀតនោះ ការជំរុញ និងបង្កើតឲ្យមានការប្រើប្រាស់ផលិតផលក្នុងស្រុកដូចជាសេវាកម្មលក់វត្ថុអនុស្សាវរីយ៍របស់សហគមន៍ ការកែច្នៃផលិតផលសហគមន៍ក៏ត្រូវបានលើកទឹកចិត្ត និងដាក់បញ្ចូលនៅក្នុងសកម្មភាពជាអាទិភាពដែរ ហើយផ្នែកនេះវាបានជួយជំរុញ ផ្តល់ការងារដែលជាប្រភពចំណូលមួយផ្នែកយ៉ាងសំខាន់សម្រាប់សហគមន៍មូលដ្ឋាននៅក្នុងតំបន់។

## គ. ពង្រឹងយុទ្ធសាស្ត្រសេវាមួយ ស្តង់ដាមួយ

## គ.១. ការរៀបចំ និងអភិវឌ្ឍមណ្ឌលព័ត៌មានទេសចរណ៍

ពិតជាមានភាពចាំបាច់ណាស់ក្នុងការចូលរួមទាក់ទាញទេសចរ និងអភិវឌ្ឍលើវិស័យទេសចរណ៍ក្នុងខេត្តក្រចេះទាំងមូល។ ជាក់ស្តែងយើងមានមណ្ឌលព័ត៌មានទេសចរណ៍មួយដែលកំពុងដំណើរការដែលស្ថិតនៅទីរួមខេត្តក្រចេះ ប៉ុន្តែនៅតាមបណ្តាសហគមន៍ទេសចរណ៍ និងរមណីយដ្ឋានមួយចំនួនធំទៀតនៅពុំទាន់មានស្នាក់ការផ្តល់ព័ត៌មានផ្លូវការនៅឡើយទេ។ ដូចនេះ ការកែលម្អលើទីតាំងចាស់ដែលមានស្រាប់ និងបង្កើតមណ្ឌលព័ត៌មានថ្មីទៀតនៅតាមរមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ គឺចាំបាច់ចាត់ជាអាទិភាព។ មណ្ឌលព័ត៌មានទេសចរណ៍ ត្រូវធានាឲ្យបាននូវព័ត៌មានសំខាន់ៗជាច្រើនដូចជាព័ត៌មានទូទៅស្តីពីតំបន់រមណីយដ្ឋាន សហគមន៍ទេសចរណ៍ ប្រវត្តិសង្ខេបស្តីពីខេត្តក្រចេះ សកម្មភាពផ្សេងៗដែលទេសចរអាចធ្វើ

និងកម្សាន្តបាន។ ព័ត៌មានដែលកំណត់ខាងលើនេះជាកត្តាទាក់ទាញទេសចរឲ្យបន្តស្នាក់នៅក្នុងខេត្តក្រចេះឲ្យកាន់តែមានរយៈពេលវែងថែមទៀត។

### គ.២. ការរៀបចំបង្គន់អនាម័យសាធារណៈ

មិនខុសពីការរៀបចំមណ្ឌលព័ត៌មានទេសចរណ៍ដែរ គឺត្រូវរៀបចំបន្ថែមនូវបង្គន់អនាម័យមានស្រាប់ដែលបានសាងសង់រួចកំពុងដាក់ឲ្យភ្ញៀវទេសចរប្រើប្រាស់។ ក្នុងនោះផងដែរ នៅតាមបណ្តារមណីយដ្ឋានទាំងចាស់ទាំងថ្មីក៏ត្រូវគិតគូរកំណត់ជាអាទិភាពចំពោះការសាងសង់បង្គន់អនាម័យផងដែររួមមានការកែលម្អបង្គន់អនាម័យរបស់រមណីយដ្ឋានអន្លង់ផ្សោតកាំពី និងការសាងសង់ថ្មីនូវបង្គន់អនាម័យចល័តតាមរមណីយ-ដ្ឋានទេសចរណ៍ធម្មជាតិព្រៃកកាំពី សហគមន៍អេកូទេសចរណ៍កោះទ្រង់ និងតាមបណ្តារមណីយដ្ឋានដែលគ្រោងបង្កើតថ្មីមួយចំនួនទៀត។

## ២.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

នៅក្នុងផ្នែកការរៀបចំទីផ្សារ និងការផ្សព្វផ្សាយផលិតផលទេសចរណ៍ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការអូសទាញទេសចរឲ្យមកទស្សនានៅក្នុងប្រទេសកម្ពុជានិយាយជារួម ក្នុងខេត្តក្រចេះនិយាយដោយឡែកឲ្យកាន់តែមានចំនួនច្រើនទ្វេរដងថែមទៀត ហើយការរៀបចំនេះទៀតសោតត្រូវផ្តោតសំខាន់លើគុណភាពផលិតផល សេវាកម្ម និងតម្លៃនៃការផ្គត់ផ្គង់។

### ក. រៀបចំសិក្សាទីផ្សារ និងតម្រូវការទេសចរ

គិតមកដល់ត្រង់ចំនុចនេះគឺពិតជាមានភាពចាំបាច់ណាស់ក្នុងការជំរុញកំណើនភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិមកទស្សនាខេត្តក្រចេះបន្ថែមទៀតពីព្រោះនៅក្នុងចំនុចនេះអាចចាត់ទុកជាកញ្ចក់មួយសម្រាប់ឆ្លុះបញ្ចាំង លាតត្រដាង ទៅដល់ទេសចរទូទៅអំពីព័ត៌មានស្តីពីធនធានសក្តានុពលទេសចរណ៍ផ្សេងៗអាចបម្រើឲ្យវិស័យទេសចរណ៍ខេត្តបាន។ ការសិក្សានេះត្រូវតែរំលេចឲ្យបាននូវព័ត៌មានសំខាន់ៗមួយចំនួនដូចជាធនធាន និងផលិតផលទេសចរណ៍ទាំងអស់ (ធនធានធម្មជាតិ វប្បធម៌ និងសកម្មភាពកម្សាន្តផ្សេងៗ) ថ្លៃលក់ផលិតផល និងការផ្សព្វផ្សាយផលិតផលជាដើម។ នៅក្នុងចំនុចខាងលើនេះត្រូវយកចិត្តទុកដាក់ចំពោះការកំណត់ពីចំនួនទេសចរឲ្យមានភាពជាក់លាក់ពិតប្រាកដពិសេសទេសចរអន្តរជាតិ ព្រោះថាភាពជាក់លាក់នៃទិន្នន័យនេះជាកត្តានាំឲ្យយើងអាចកំណត់ជាយុទ្ធសាស្ត្រទីផ្សារបានច្បាស់លាស់ ចំទិសដៅដែលទេសចរត្រូវការ។ ការកំណត់បែងចែកប្រភេទទីផ្សារតម្រូវការទេសចរឲ្យបានច្បាស់លាស់ ក៏គួរត្រូវបានចាត់ចូលជាសកម្មភាពយុទ្ធសាស្ត្រដែរ។

### ខ. បង្កើតគេហទំព័រផ្សព្វផ្សាយទេសចរណ៍

គឺជាយន្តការមួយយ៉ាងសំខាន់ក្នុងការពង្រីកវិសាលភាពទីផ្សារទេសចរណ៍នៅក្នុងខេត្តក្រចេះទាំងមូលដែលរួមទាំងតំបន់ចាស់ៗនិងតំបន់គោលដៅដែលបានបង្កើតថ្មី។ ចំពោះការបង្កើតគេហទំព័រនេះគឺត្រូវប្រមូលទិន្នន័យឲ្យបានគ្រប់ជ្រុងជ្រោយទូលំទូលាយដើម្បីងាយស្រួលក្នុងការចងក្រងផ្សព្វផ្សាយ បន្ថែមលើ

នេះទៅទៀតនោះ ការធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីទេសចរណ៍ក៏ត្រូវអនុវត្តជាប្រចាំផងដែរដើម្បីការអនុវត្តផែនការយុទ្ធសាស្ត្រខាងលើកាន់តែមានប្រសិទ្ធិភាពខ្ពស់។ សកម្មភាពចំនួន៣ផ្សេងទៀត ត្រូវបានកំណត់ដាក់ចេញបន្ថែមដូចខាងក្រោមទៀតៈ

- ការបង្កើតសៀវភៅមគ្គុទ្ទេសក៏ទេសចរណ៍ និងទស្សនាវដ្តីទេសចរណ៍ខេត្តក្រចេះ
- ការរៀបចំស្ប៉ូតវីដេអូ និងឯកសារផ្សព្វផ្សាយទេសចរណ៍
- ជំរុញផ្សព្វផ្សាយព្រឹត្តិការណ៍ទេសចរណ៍

## ២.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

តាមភូមិសាស្ត្រជាក់ស្តែង ក្រចេះ ជាខេត្តមួយដែលស្ថិតនូវចំនុចកណ្តាលរវាងខេត្តនានានៃភូមិភាគឦសានប្រទេសកម្ពុជាដែលរួមមានខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ ដោយស្ថិតលើទីតាំងអំណោយផលខាងលើនេះតំបន់គោលដៅក្នុងខេត្តក្រចេះអាចតភ្ជាប់ទៅកាន់ខេត្តនៅតាមបណ្តាភូមិភាគឦសានសម្រួលការធ្វើដំណើរទេសចរបានយ៉ាងល្អប្រសើរ។ លើសពីនេះទៅទៀតនោះ ទេសចរដែលមកទស្សនាខេត្តក្រចេះក៏អាចភ្ជាប់ដំណើរកម្សាន្តរបស់ពួកគេទៅកាន់តំបន់ប្រាសាទព្រះវិហារ និងអង្គរវត្តថែមទាំងអាចបន្តដំណើរចាកចេញតាមរយៈការហោះហើរពីខេត្តសៀមរាបទៅកាន់តំបន់គោលដៅប្រទេសផ្សេងៗទៀតក្នុងតំបន់ជុំវិញបានផងដែរ។ ដើម្បីឲ្យយុទ្ធសាស្ត្រខាងលើអនុវត្តបានប្រកបដោយភាពជោគជ័យខ្ពស់ សកម្មភាពចាំបាច់មួយចំនួនត្រូវបានកំណត់ដូចខាងក្រោមៈ

### ក. បង្កើតកម្មវិធីទូរស័ព្ទឆ្លាតវៃ (Mobile App)

អាចជាវិធីសាស្ត្រមួយយ៉ាងល្អប្រសើរបង្កភាពងាយស្រួលទៅដល់ទេសចរលើការស្វែងយល់បន្ថែមពីតំបន់គោលដៅទេសចរណ៍ក្នុងខេត្តក្រចេះដែលពួកគាត់ចង់ទៅទស្សនា។ កម្មវិធីនេះទៀតសោតត្រូវផ្តល់លទ្ធភាពទៅដល់ទេសចរចំពោះការកក់ទុកមុននូវសេវាកម្មផ្សេងៗទៀតតាមតំបន់ទេសចរណ៍ ដូចជាការកក់សំបុត្រចូលទស្សនា ការកក់សេវាកម្មទូក ម្ហូបអាហារ និងការស្នាក់នៅជាដើម។

### ខ. រៀបចំកញ្ចប់ខ្សែទស្សនៈកិច្ចទេសចរណ៍

ត្រូវតែមានកិច្ចសហការពីតាមបណ្តាមន្ទីរទេសចរណ៍ខេត្តនៅតំបន់ជុំវិញ និងជាមួយក្រុមហ៊ុនទេសចរណ៍ផ្សេងៗទៀតជាចាំបាច់។ ការរៀបចំកញ្ចប់ខ្សែទស្សនៈកិច្ច ត្រូវកំណត់ឲ្យបានច្បាស់លាស់លើសេវាកម្ម ធនធាន ពេលវេលា និងតម្លៃកញ្ចប់នីមួយៗ។ ក្រោយពីបានរៀបចំកញ្ចប់ខ្សែទស្សនៈកិច្ចទេសចរណ៍បានរួចហើយមន្ទីរទេសចរណ៍ខេត្តក្រចេះ និងភាគីពាក់ព័ន្ធត្រូវជួយផ្សព្វផ្សាយពីកញ្ចប់ខ្សែទស្សនៈកិច្ចនេះឲ្យបានទូលំទូលាយទៅតាមបណ្តាក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ជាតិ អន្តរជាតិ ហើយការកែសម្រួល និងធ្វើបច្ចុប្បន្នភាពចំពោះកញ្ចប់ខ្សែទស្សនៈកិច្ចត្រូវអនុវត្តជាប់ជាប្រចាំទៅតាមការប្រែប្រួលស្ថានភាពតម្លៃទីផ្សារ ក៏ដូចជាស្ថានភាពប្រែប្រួលសំខាន់ៗឯទៀតៗ។

### គ. រៀបចំផែនទីទេសចរណ៍ និងផ្ទាំងផ្សព្វផ្សាយទេសចរណ៍

វាពិតជាមានសារៈសំខាន់ដើម្បីទាក់ទាញទេសចរ។ ការរៀបចំផែនទីទេសចរណ៍ខេត្តក្រចេះត្រូវកំណត់ជាពីរផ្នែកៈ ទី១ គឺផែនទីទេសចរណ៍សម្រាប់ខេត្តក្រចេះទាំងមូលរាល់តំបន់ទេសចរណ៍មានក្នុងខេត្តក្រចេះទាំងអស់ត្រូវបានកំណត់នៅក្នុងផ្ទាំងផែនទីទេសចរណ៍រួមមួយ។ ទី២ គឺផែនទីទេសចរណ៍តាមតំបន់ទេសចរណ៍នីមួយៗ ផែនទីនេះត្រូវរៀបចំឡើងសម្រាប់តែតំបន់ទេសចរណ៍ជាក់លាក់តែប៉ុណ្ណោះ។ ឧទាហរណ៍ៈ ផែនទីទេសចរណ៍សហគមន៍អេកូទេសចរណ៍កោះទ្រង់ ផែនទីទេសចរណ៍រមណីយដ្ឋានទឹកជ្ជរកាំពី។ល។ ការរៀបចំផែនទីទេសចរណ៍គឺត្រូវបង្ហាញឲ្យឃើញនូវទីតាំងចំងាយផ្លូវ រយៈពេល មធ្យោបាយធ្វើដំណើរនិងសេវាកម្មផ្សេងៗដែលទេសចរអាចទស្សនាកម្សាន្តនៅក្នុងតំបន់នោះបាន។ ដោយឡែកការរៀប-ចំផ្ទាំងផ្សព្វផ្សាយទេសចរណ៍ក៏មិនខុសគ្នាពីផែនទីទេសចរណ៍ដែរ ក៏គឺត្រូវតែកំណត់ឲ្យឃើញច្បាស់ពីគំនូសសញ្ញាបង្ហាញទិស រយៈចំងាយ និងពេលវេលា។ល។ ក្រៅពីនេះផ្ទាំងផ្សព្វផ្សាយទេសចរណ៍អាចដាក់បង្ហាញពីការផ្សព្វផ្សាយអប់រំស្តីពីទេសចរណ៍ បរិស្ថានផងដែរ។

### ឃ. ជំរុញ និងសម្រួលការដឹកជញ្ជូនទេសចរ

ខេត្តក្រចេះមានលក្ខណៈល្អប្រសើរណាស់ ដោយអាចតភ្ជាប់ផ្លូវទៅកាន់ខេត្តដទៃទៀតនៅតំបន់ភូមិភាគឦសានបាន។ មធ្យោបាយធ្វើដំណើរជាកត្តាមួយដ៏យ៉ាងសំខាន់ក្នុងការទាក់ទាញ និងបំពេញសេចក្តីត្រូវការរបស់ទេសចរបានមួយកម្រិតធំផងដែរ។ ចំពោះមធ្យោបាយធ្វើដំណើរវិញ គឺផ្តោតសំខាន់ទាំងផ្លូវគោក ផ្លូវអាកាស និងផ្លូវទឹក។ សម្រាប់ស្ថានភាពជាក់ស្តែងចំពោះការធ្វើដំណើររបស់ទេសចរក្នុងខេត្តក្រចេះ គឺទាមទារឲ្យមានការកែលម្អចំណុចមួយចំនួន ក្នុងនោះរួមមានការរៀបចំចំណតរថយន្តទេសចរ រថ-យន្តក្រុង និងរថយន្តតូចៗដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ។ ខេត្តក្រចេះស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គពីព្រំប្រទល់ខេត្តកំពង់ចាមរហូតដល់ព្រំដែនប្រទេសឡាវឆ្លងកាត់ខេត្តស្ទឹងត្រែង ហើយលក្ខណ្ឌបែបនេះជាអំណោយផលមួយទាក់ទាញទេសចរ ដែលមានន័យថាទេសចរអាចទស្សនាកម្សាន្តទេសភាពធនធានធម្មជាតិដ៏ស្រស់ត្រកាលតាមដងទន្លេមេគង្គ។ ការរៀបចំឲ្យមានកំពង់ផែ ចំណតទូកទេសចរណ៍ក្នុងខេត្តក្រចេះពិតជាល្អប្រសើរបំផុត។ លើសពីនេះទៅទៀតនោះ ខេត្តក្រចេះមានព្រំដែនគោកជាប់ជាមួយនឹងប្រទេសវៀតណាម។ ដូច្នេះការកែលម្អស្លាកសញ្ញាព័ត៌មាន និងការសង់អគារសម្រាករយៈពេលខ្លីសម្រាប់ទេសចរក៏ត្រូវរួមសហការរៀបចំជាមួយភាគីវៀតណាមផងដែរ។

## ២.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

សន្តិសុខ ភាពសុខសាន្ត ស្ថេរភាពនយោបាយផ្តល់នូវភាពសប្បាយរីករាយជូនដល់ទេសចរ។ តាមរយៈនេះ រដ្ឋបាលខេត្ត និងផ្នែកដែលពាក់ព័ន្ធអាចផ្តល់ជូនពួកគេតាមរយៈចំណុចគន្លឹះដូចខាងក្រោមៈ

- ពង្រឹងសុវត្ថិភាពភ្ញៀវទេសចរទាំងការធ្វើដំណើរ និងការស្នាក់នៅស្របតាមគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងត្រូវបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់
- ពង្រឹង និងចងក្រងប្រពន្ធ័សន្តិសុខ សុវត្ថិភាពទេសចរដល់តំបន់គោលដៅទេសចរណ៍សំខាន់ៗ ដោយសហការយ៉ាងល្អប្រសើរជាមួយប៉ូលិសទេសចរណ៍ អាជ្ញាធរមូលដ្ឋានផ្ទាល់

- បន្តជំរុញដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទាំងអស់ ត្រូវទទួលខុសត្រូវខ្ពស់លើការងារអាជីវកម្មរបស់ខ្លួនចូលរួមផ្តល់ព័ត៌មានជាបន្ទាន់ពេលមានក្នុងករណីកើតឡើងផ្សេងៗ
- បង្កើតប្រព័ន្ធទំនាក់ទំនងតាមតំបន់ទេសចរណ៍សំខាន់ៗ កន្លែងផ្តល់ព័ត៌មាន និងបំពាក់សម្ភារៈសង្គ្រោះបន្ទាន់ក្នុងករណីមានកើតគ្រោះថ្នាក់ ឬហេតុការណ៍ផ្សេងៗដល់ទេសចរ
- ជំរុញអប់រំសហគមន៍ឲ្យយល់ដឹងបន្ថែមពីសុវត្ថិភាពភ្ញៀវទេសចរ សង្គ្រោះបន្ទាន់ ដោយមានការចូលរួមពីភាគីពាក់ពន្ធ័នៅតាមតំបន់ទេសចរណ៍
- អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវសហការគ្នាចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ត្រូវលុបបំបាត់ភាពអនាធិបតេយ្យផ្សេងៗ
- ជំរុញលើកកម្ពស់គុណភាពជាអាទិភាពចំពោះសុវត្ថិភាពចំណីអាហារអនាម័យជាពិសេសនៅតាមតំបន់គោលដៅសំខាន់ៗដោយមន្ទីរទេសចរណ៍ខេត្តត្រូវធ្វើការសហការជាមួយនឹងមន្ទីរសុខាភិបាល សហការជាមួយអាជ្ញាធរដែនដីត្រួតពិនិត្យ អប់រំជាប្រចាំតាមកន្លែងលក់ដូរម្ហូបអាហារ ដូចជាអាហារដ្ឋាន ភោជនីយដ្ឋាន។

## ២.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង

ដើម្បីធានាបានការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាពយើងមានយន្តការមួយចំនួនដើម្បីអនុវត្តៈ

- ជំរុញការផ្សព្វផ្សាយបទដ្ឋានគតិយុត្ត និងយន្តការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
- ជំរុញការធ្វើអាជ្ញាបណ្ណទេសចរណ៍តាមយន្តការច្រកចេញចូលតែមួយ
- ចុះធ្វើអធិការកិច្ចតាមមូលដ្ឋានអាជីវកម្មទេសចរណ៍
- សហការជាមួយសមត្ថកិច្ចពាក់ពន្ធ័ទាំងអស់ដើម្បីជំរុញដល់ប្រតិបត្តិករទេសចរណ៍ក្នុងខេត្តឲ្យចូលរួមគោរពច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តទាំងឡាយដែលក្រសួងបានដាក់ចេញ
- អប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ បទដ្ឋានគតិយុត្តនានាដល់ប្រតិបត្តិ-ករទេសចរណ៍នៅទូទាំងខេត្ត
- ធ្វើការជាមួយគណៈកម្មការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះជំរុញ និងអនុវត្តបទដ្ឋានគតិយុត្តនានាឲ្យមានប្រសិទ្ធភាព ។

## ២.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍

ធនធានមនុស្សជាផ្នែកមួយដ៏សំខាន់មិនអាចខ្វះបានក្នុងដំណើរការនៃការអភិវឌ្ឍ ការជំរុញឲ្យវិស័យទេសចរណ៍ខេត្តក្រចេះមានការរីកចម្រើន។ ការបណ្តុះបណ្តាលធនធានមនុស្សជាចលករមួយជំរុញកិច្ចដំណើរការអភិវឌ្ឍប្រកបដោយគុណភាពស្តង់ដា និងមានចីរភាព។ ជាយុទ្ធសាស្ត្រដើម្បីជួយលើកកម្ពស់វិស័យទេសចរណ៍ខេត្តក្រចេះឲ្យមានដំណើរការល្អ និងរីកចម្រើន យើងដែលជាអ្នកអនុវត្ត ស្ថាប័នពាក់ពន្ធ័ក្នុងខេត្ត វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលត្រូវជំរុញបង្កើតឲ្យមានសាលាបណ្តុះបណ្តាល

វិជ្ជាជីវៈទេសចរណ៍មួយកន្លែងប្រចាំនៅក្នុងតំបន់ភូមិភាគឦសាន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍បន្ថែមប្រកបដោយគុណភាព ដែលជាកន្លែងប្រមូលផ្តុំធនធានមនុស្សមកពីគ្រប់ទិសទីក្នុងភូមិភាគឦសាន។ ការលើកកម្ពស់ផ្នែកយេនឌ័រប្រកបដោយសមធម៌ជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍។

ទន្ទឹមនឹងនោះយើងត្រូវធ្វើការដោះស្រាយបញ្ហាខ្វះខាតពេលបច្ចុប្បន្ននេះ ដោយការពង្រឹងធនធានមនុស្សតាមផ្នែករួមមាន ៖

- ជំរុញផ្សព្វផ្សាយយុទ្ធនាការបុគ្គលិកម្នាក់ជំនាញមួយ
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីបង្គោល
- បណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ស្តង់ដាសមត្ថភាពអាស៊ានក្នុងក្របខ័ណ្ឌ MRA-TP
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកកំពុងបម្រើការងារ
- បណ្តុះបណ្តាលមគ្គុទ្ទេសក៏ទេសចរណ៍ និងសហគមន៍ទេសចរណ៍
- ជំរុញបង្កើតមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- បណ្តុះបណ្តាល ផ្សព្វផ្សាយសហគ្រិនភាព សមភាពយេនឌ័រក្នុងវិស័យទេសចរណ៍
- ការរៀបចំឲ្យមានដំណើរទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារទេសចរណ៍ដល់មន្ត្រីរាជការ ជនបង្គោលសហគមន៍ ។

## ២.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍

តម្រូវការចាំបាច់ដើម្បីឲ្យវិស័យទេសចរណ៍ខេត្តក្រចេះលេចធ្លោឡើងក្លាយជាខេត្តគោលដៅអេកូទេសចរណ៍ប្រចាំភូមិភាគឦសាន យន្តការនៃការជំរុញលើកទឹកចិត្តឲ្យមានការចូលរួមក្នុងវិស័យទេសចរណ៍គឺចាំបាច់បំផុត។ ដោយយល់ឃើញថាទេសចរណ៍ខេត្តក្រចេះ នៅមានចំណុចជាច្រើនពុំទាន់មានលក្ខណៈល្អប្រសើរដូចជាផលិតផលទេសចរណ៍នៅមានកម្រិត សេវាកម្មទេសចរណ៍ពុំទាន់មានលក្ខណៈស្តង់ដាត្រឹមត្រូវពុំទាន់អាចបំពេញតម្រូវការពេញចិត្តរបស់ភ្ញៀវទាំងស្រុងនោះ យុទ្ធសាស្ត្រទាំងឡាយនៅក្នុងផែនការនេះគឺចាំបាច់បំផុតចំពោះការចូលរួមពីគ្រប់វិស័យជាពិសេសផ្នែកឯកជនដើម្បីសម្រេចបានដល់គោលដៅខាងលើ។

ដើម្បីឲ្យការអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះមានការរីកចម្រើន អភិវឌ្ឍប្រកបដោយនិរន្តរភាពមានដូចតទៅ៖

- ត្រូវជំរុញស្វែងរកអ្នកវិនិយោគ និងដៃគូអភិវឌ្ឍន៍ទាំងក្នុងស្រុក និងក្រៅស្រុកជាពិសេសជំរុញលើកទឹកចិត្តផ្តល់អាទិភាពដល់អ្នកវិនិយោគក្នុងស្រុកជាមុនព្រោះថាចំណូលដែលបានមកនឹងមិនអាចលេចធ្លាយ (រូបិយវត្ថុ)ទៅក្រៅប្រទេស។
- សម្រួលលើកទឹកចិត្តដល់ប្រតិបត្តិករក្នុងខេត្តឲ្យធ្វើការវិនិយោគបម្រើឲ្យវិស័យទេសចរណ៍ជាលក្ខណៈទ្រង់ទ្រាយតូច ឬមធ្យម បង្កលក្ខណៈងាយស្រួលជូនដល់ពួកគាត់មុនពេលដាក់ទុនវិនិយោគដូចជាលិខិតស្នាមស្នើសុំធ្វើអាជីវកម្ម បែបបទគតិយុត្តិផ្សេងៗ

- មន្ទីរទេសចរណ៍ដែលជាមន្ទីរសាមីត្រូវធ្វើការសហការជាមួយខេត្ត ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំចងក្រងព័ត៌មានផែនការវិនិយោគជាលក្ខណៈទ្រង់ទ្រាយតូច មធ្យម និងធំឲ្យបានលម្អិតច្បាស់លាស់ ផ្សព្វផ្សាយស្វែងរកដៃគូវិនិយោគដែលចាប់អារម្មណ៍ក្នុងវិស័យទេសចរណ៍។
- ជាពិសេសនោះការបង្កើតយន្តការរដ្ឋឯកជនក្នុងវិស័យទេសចរណ៍។

## ២.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

### ក. ការអភិរក្ស

ខេត្តក្រចេះ ត្រូវគេចាត់ទុកជាគោលដៅទេសចរណ៍ធម្មជាតិនៅក្នុងភូមិភាគឦសាននៃប្រទេសកម្ពុជា ដូច្នេះការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះពឹងផ្អែកទាំងស្រុងលើធនធាន និងសម្បត្តិវប្បធម៌ដែលមានស្រាប់នៅក្នុងខេត្ត ធនធានធម្មជាតិ ជីវៈចម្រុះគ្រប់ប្រភេទ ទំនៀមទំលាប់ប្រពៃណីរបស់បងប្អូនជនជាតិ និងការធ្វើរបរកសិកម្ម។ ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយអភិវឌ្ឍទេសចរណ៍ខេត្តក្រចេះឲ្យមានការរីកចម្រើនកាន់តែល្អប្រសើរប្រកបដោយនិរន្តរភាព ការចូលរួមក្នុងកិច្ចការពារសម្បត្តិវប្បធម៌ និងធនធានដែលមានស្រាប់នៅក្នុងខេត្តជាការងារចំបង និងការទទួលខុសត្រូវរបស់យើងគ្រប់គ្នា។ ជាយុទ្ធ-សាស្ត្រក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តក្រចេះចាំបាច់ត្រូវធ្វើការរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធ មានមន្ទីរបរិស្ថាន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និងអង្គការនានាក្នុងខេត្ត ដោយធ្វើការរៀបចំផែនការរួមគ្នាដើម្បីធានាដល់ការងារគ្រប់គ្រង និងអភិរក្សធនធានសម្បត្តិវប្បធម៌ប្រកបដោយចីរភាព។

### ខ. ការគ្រប់គ្រងកាកសំណល់ និងបរិស្ថាន

ការលើកកម្ពស់គុណភាព រៀបចំបរិស្ថានឲ្យបានប្រសើរជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្ត និងការផ្តល់នូវផាសុខភាពដល់ភ្ញៀវផងដែរ។ ជាយុទ្ធសាស្ត្រយើងត្រូវជំរុញរៀបចំសកម្មភាពទាំងឡាយ ក្នុងន័យអប់រំលើកកម្ពស់ចំណេះដឹងស្តីពីបរិស្ថាន ដោយអនុវត្តឆ្ពោះទៅរកសោភណ្ឌភាពទីក្រុងស្អាត និងភាពបៃតងជានិច្ចតាមតំបន់រមណីយដ្ឋានទេសចរណ៍ ដោយការបង្កើតកម្មវិធីចូលរួមដាំដើមឈើឡើងវិញ ការបង្កើតសួនអាពាហ៍ពិពាហ៍ដោយរៀបចំឲ្យមានជាលក្ខណៈស្តង់ដាតាមច្បាប់របស់ក្រសួងដែលបានដាក់ចេញ ។

ដើម្បីគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយ កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ និងចលនាប្រលងប្រណាំង “ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ” និងស្របតាមសូចនាករស្តង់-ដាទីក្រុងស្អាតចាំបាច់ណាស់គឺត្រូវជំរុញដល់ការគ្រប់គ្រងកាកសំណល់ផ្សេងៗតាមដងផ្លូវទីប្រជុំជន និងតំបន់គោលដៅទេសចរណ៍ ត្រូវតែមានភាពស្រស់ស្អាត មានសោភណ្ឌភាព ដោយរៀបចំឲ្យមានរបៀបរៀបរយប្រកបដោយការទទួលខុសត្រូវខ្ពស់។ នៅក្នុងនោះផងដែរ ខេត្តក្រចេះដែលមានសាលាក្រុង មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត មន្ទីរបរិស្ថានខេត្ត ត្រូវធ្វើការរួមគ្នាសិក្សាឲ្យបានច្បាស់លាស់លើការងារគ្រប់គ្រងកាកសំណល់ និងការរៀបចំផែនការមេបង្កើតឲ្យមានទីលានសម្រាប់ចាក់សំរាមរបស់ខេត្ត។

## ៣. ផែនការសកម្មភាពសម្រាប់ ឆ្នាំ២០២១-២០២៥

ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តក្រចេះ បានលើកឡើងទាំង៨ចំណុចខាងលើបង្ហាញឲ្យឃើញច្បាស់ពីដំណើរការអភិវឌ្ឍដែលក្នុងនោះយើងសូមលើកឡើងនូវសកម្មភាពការងារជាអាទិភាពដោយលំអិតនៅក្នុងចំណុចនីមួយៗដូចខាងក្រោម៖

### ៣.១ ការអភិវឌ្ឍផលិតផលទេសចរណ៍

#### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- ***ការអភិវឌ្ឍសម្បទាទេសចរណ៍តំបន់អាទិភាព***
  - រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តក្រចេះ និងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់សំខាន់ៗក្នុងខេត្ត
  - ខិតខំរកមូលនិធិដើម្បីសាងសង់មណ្ឌលផ្តល់ព័ត៌មានទេសចរណ៍នៅលើទីតាំងដែលសាលាខេត្តបានកំណត់ទុកជូនមន្ទីរទេសចរណ៍
  - រៀបចំពង្រឹងផលិតផល និងសេវាកម្មទេសចរណ៍ សហគមន៍អេកូទេសចរណ៍នានា
  - រៀបចំតំបន់ទេសចរណ៍សំខាន់ៗប្រកបដោយសក្តានុពលស្របតាមស្តង់ដារអប្បរមារមណីយដ្ឋានដែលក្រសួងបានកំណត់។

#### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- ***ការអភិវឌ្ឍសម្បទាទេសចរណ៍តំបន់អាទិភាព***
  - រៀបចំពង្រឹងផលិតផល និងសេវាកម្មទេសចរណ៍ សហគមន៍អេកូទេសចរណ៍
  - រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តក្រចេះ និងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់សំខាន់ៗ ក្នុងខេត្ត
  - រៀបចំតំបន់ទេសចរណ៍សំខាន់ៗ និងមានសក្តានុពលដើម្បីទទួលបាននូវស្តង់ដាអប្បបរមាមណីយដ្ឋានដែលក្រសួងបានកំណត់។

#### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- ***ការអភិវឌ្ឍសម្បទាទេសចរណ៍តាមតំបន់ធម្មជាតិ***
  - រៀបចំអភិវឌ្ឍន៏ផលិតផល សេវាកម្មទេសចរណ៍បន្ថែម និងធ្វើការពង្រឹងសហគមន៍អេកូទេសចរណ៍
  - សិក្សាស្រាវជ្រាវតំបន់សក្តានុពលទេសចរណ៍តាមតំបន់ធម្មជាតិ និងធ្វើការអភិវឌ្ឍតំបន់ព្រៃ ជំរកសត្វស្លាបទឹក ជីវៈចម្រុះ និងអភិវឌ្ឍផលិតផលសេវាកម្មបន្ថែម

- ជំរុញរៀបចំព្រឹត្តិការណ៍ទេសចរណ៍ និងការប្រណាំងទូក កង់ ប្រចាំខេត្ត។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ *ការអភិវឌ្ឍសម្បទាទេសចរណ៍តាមតំបន់ធម្មជាតិ*

- រៀបចំអភិវឌ្ឍន៍ផលិតផល សេវាកម្មទេសចរណ៍បន្ថែម និងធ្វើការពង្រឹងសហគមន៍អេកូទេសចរណ៍
- សិក្សាស្រាវជ្រាវតំបន់សក្តានុពលទេសចរណ៍តាមតំបន់ធម្មជាតិ និងធ្វើការអភិវឌ្ឍតំបន់ព្រៃ ជំរកសត្វស្លាបទឹក ជីវៈចម្រុះ និងអភិវឌ្ឍន៍ផលិតផល សេវាកម្មទេសចរណ៍បន្ថែម
- ជំរុញការរៀបចំព្រឹត្តិការណ៍ទេសចរណ៍។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ *ការអភិវឌ្ឍទេសចរណ៍ក្រុង និងជុំវិញក្រុង*

- រៀបចំកែលម្អក្រុងក្រចេះ ឲ្យមានភាពបៃតង និងអភិវឌ្ឍច្រាំងមាត់ទន្លេ(សួនច្បារ) ក្នុងក្រុង
- រៀបចំបង្កើតកន្លែងកម្សាន្ត និងរៀបចំដំណើរទស្សនៈកិច្ចជុំវិញក្រុងក្រចេះ
- រៀបចំសាងសង់បង្គន់អនាម័យសាធារណៈក្នុងក្រុងក្រចេះឲ្យមានលើសពីមួយ
- រៀបចំចំណតរថយន្តឲ្យមានសណ្តាប់ធ្នាប់
- រៀបបំពាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅទីសាធារណៈសំខាន់ៗក្នុងក្រុង។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ *ការអភិវឌ្ឍទេសចរណ៍ក្រុង និងជុំវិញក្រុង*

- រៀបចំកែលម្អក្រុងក្រចេះ ឲ្យមានភាពបៃតង និងអភិវឌ្ឍច្រាំងមាត់ទន្លេ(សួនច្បារ)ក្នុងក្រុង
- រៀបចំចំណតរថយន្តឲ្យមានសណ្តាប់ធ្នាប់
- រៀបចំដាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅទីសាធារណៈសំខាន់ៗក្នុងក្រុង។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ *ស្រាវជ្រាវប្រវត្តិតំបន់រមណីយដ្ឋានទេសចរណ៍ និងពិធីបុណ្យផ្សេងៗ*

- ប្រមូលព័ត៌មាន ចងក្រងឯកសារពិធីបុណ្យផ្សេងៗ និងប្រវត្តិសំខាន់ៗដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តក្រចេះ

- រៀបចំបកប្រែ និងបោះពុម្ពឯកសារពិធីផ្សេងៗ និងប្រវត្តិសំខាន់ៗដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តក្រចេះទៅក្នុងបណ្តាញទំនាក់ទំនងដូចជា(គេហទំព័រទេសចរណ៍ និងទស្សនាវដ្តីជាដើម)។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ *ស្រាវជ្រាវប្រវត្តិតំបន់រមណីយដ្ឋានទេសចរណ៍ និងពិធីបុណ្យផ្សេងៗ*

- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្នុងការស្រាវជ្រាវពីរបាំប្រពៃណីប្រចាំខេត្ត និងនៅតាមភូមិឃុំ ស្រុក ក្រុង
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការចងក្រងរឿងព្រេងនិទាននានាទាក់ទងនឹងភូមិសាស្ត្រក្នុងខេត្ត
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្នុងការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិ-សាស្ត្រនៅក្នុងក្រុង និងស្រុកនានា តាមទីទួលប្រាសាទ។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ *ការអភិវឌ្ឍផលិតផលទេសចរណ៍បន្ថែម*

- រៀបចំបង្កើតសមាគមវត្ថុអនុស្សាវរីយ៍ និងផលិផលសហគមន៍ខេត្តក្រចេះ
- រៀបចំបង្កើតមណ្ឌលផ្សព្វផ្សាយ និងគាំទ្រដល់វត្ថុអនុស្សាវរីយ៍ ផលិតផលសហគមន៍ខេត្តក្រចេះ
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគបង្កើតមជ្ឈមណ្ឌលកម្សាន្តនានាក្នុងខេត្តក្រចេះ។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ *ការអភិវឌ្ឍផលិតផលទេសចរណ៍បន្ថែម*

- រៀបចំបង្កើតសមាគមវត្ថុអនុស្សាវរីយ៍ និងផលិផលសហគមន៍ខេត្តក្រចេះ
- រៀបចំបង្កើតមណ្ឌលផ្សព្វផ្សាយ និងគាំទ្រដល់វត្ថុអនុស្សាវរីយ៍និងផលិតផលសហគមន៍ខេត្តក្រចេះ
- ជំរុញទឹកចិត្តដល់អ្នកវិនិយោគបង្កើតមជ្ឈមណ្ឌលកម្សាន្តនានាក្នុងខេត្តក្រចេះ
- រៀបចំបង្កើតផ្សាររាត្រីប្រចាំខេត្តក្រចេះ។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ *ការជំរុញគុណភាពផលិតផល និងសេវាកម្មទេសចរណ៍*

- ផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ដូចជា៖ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយ-ដ្ឋាន អាហារដ្ឋាន និងកន្លែងកម្សាន្តនានាក្នុងការពង្រឹងគុណភាពទាំងសេវាកម្ម និងការធ្វើអនាម័យ

- វគ្គបណ្តុះបណ្តាលដល់សហគមន៍ទេសចរណ៍ពីអនាម័យនិងការផ្តល់សេវាកម្ម។

### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- ផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ដូចជាៈ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន ភោជនីយដ្ឋាន និងកន្លែងកម្សាន្តនានាក្នុងការពង្រឹងគុណភាពសេវាកម្ម ការធ្វើអនាម័យ
- រៀបចំបង្កើតសមាគមមគ្គុទ្ទេសក៏ទេសចរណ៍ខេត្តក្រចេះ ការកំណត់ឲ្យមានឯកសណ្ឋានច្បាស់លាស់ និងការពង្រឹងគុណភាពសេវាកម្ម
- បណ្តុះបណ្តាលដល់សហគមន៍ទេសចរណ៍ពីអនាម័យ និងការផ្តល់សេវាកម្ម។

## ៣.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តក្រចេះ និងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់ទេសចរណ៍សំខាន់ៗក្នុងខេត្ត
- រៀបចំអភិវឌ្ឍផលិតផល សេវាកម្មទេសចរណ៍បន្ថែម និងធ្វើការពង្រឹងសហគមន៍អេកូទេសចរណ៍
- សិក្សាស្រាវជ្រាវតំបន់សក្តានុពលទេសចរណ៍តាមតំបន់ធម្មជាតិ និងធ្វើការអភិវឌ្ឍតំបន់ព្រៃ ជំរកសត្វស្លាបទឹក ជីវៈចម្រុះ និងអភិវឌ្ឍផលិតផល និងសេវាកម្មទេសចរណ៍បន្ថែម
- សាងសង់មណ្ឌលព័ត៏មានទេសចរណ៍នៅលើទីតាំងដែលសាលាខេត្តបានកំណត់ទុកឲ្យមន្ទីរទេសចរណ៍
- រៀបចំពង្រឹងផលិតផល និងសេវាកម្មទេសចរណ៍សហគមន៍អេកូទេសចរណ៍នានា
- រៀបចំតំបន់ទេសចរណ៍ដែលមានសក្តានុពលដើម្បីទទួលបាននូវស្តង់ដារអប្បបរមារមណីយដ្ឋានដែលក្រសួងទេសចរណ៍បានកំណត់
- ជំរុញរៀបចំព្រឹត្តិការណ៍ទេសចរណ៍
- រៀបចំកែលម្អក្រុងក្រចេះ ឲ្យមានភាពបៃតង និងអភិវឌ្ឍច្រាំងមាត់ទន្លេ(សួនច្បារ) ក្នុងក្រុង
- រៀបចំបង្កើតកន្លែងកម្សាន្ត និងរៀបចំដំណើរទស្សនកិច្ចជុំវិញក្រុងក្រចេះ
- រៀបចំបង្គន់អនាម័យសាធារណៈក្នុងក្រុងក្រចេះឲ្យបានលើសពីមួយ
- រៀបចំចំណតរថយន្តឲ្យមានសណ្តាប់ធ្នាប់នៅក្នុងក្រុងក្រចេះ និងតាមតំបន់គោលដៅទេសចរណ៍សំខាន់ៗ
- ដាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅទីសាធារណៈសំខាន់ៗ ក្នុងក្រុង និងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ

- ប្រមូលព័ត៌មាន និងចងក្រងឯកសារពិធីបុណ្យផ្សេងៗ ប្រវត្តិសំខាន់ៗដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តក្រចេះ
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការស្រាវជ្រាវពីរបាំប្រពៃណីប្រចាំខេត្ត និងនៅតាមភូមិឃុំ ស្រុក ក្រុង
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការចងក្រងរឿងព្រេងនិទាននានា ទាក់ទងនឹងភូមិសាស្ត្រក្នុងខេត្ត
- សហការជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការរៀបចំ និងអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនៅក្នុងក្រុង និងស្រុកនានា ដូចជាទីទួលប្រាសាទ
- ផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ មានដូចជា សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន ភោជនីយដ្ឋាន និងកន្លែងកម្សាន្តនានាក្នុងការពង្រឹងគុណភាព ទាំងសេវា និងអនាម័យ
- បណ្តុះបណ្តាលដល់ទេសចរណ៍សហគមន៍ពីអនាម័យ និងការផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាពខ្ពស់
- រៀបចំសិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍ខេត្តក្រចេះ ដោយសិក្សាលម្អិតពីប្រភេទភ្ញៀវទេសចរដែលចូលមកកម្សាន្ត និងតម្រូវការរបស់ភ្ញៀវលើផលិតផលទេសចរណ៍
- រៀបចំបង្កើតគេហទំព័រព័ត៌មានទេសចរណ៍ខេត្តក្រចេះ និងធ្វើការផ្សព្វផ្សយព័ត៌មានផលិតផលទេសចរណ៍ តំបន់សក្តានុពលទេសចរណ៍ក្នុងខេត្តទាំងមូលតាមរយៈភ្ជាប់ជាមួយគេហទំព័រល្បីៗរបស់ក្រុមហ៊ុន ការីទេសចរណ៍សំខាន់ៗ ទាំងក្នុងប្រទេស និងក្រៅប្រទេស
- រៀបចំបង្កើតសៀវភៅមគ្គុទ្ទេសក៏ទេសចរណ៍សម្រាប់ខេត្តក្រចេះទាំងមូល។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តក្រចេះ និងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់ទេសចរណ៍សំខាន់ៗក្នុងខេត្ត
- រៀបចំអភិវឌ្ឍផលិតផល សេវាកម្មទេសចរណ៍បន្ថែម និងធ្វើការពង្រឹងសហគមន៍អេកូទេសចរណ៍
- រៀបចំបង្កើតសមាគមមគ្គុទ្ទេសក៏ទេសចរណ៍ខេត្តក្រចេះ ដោយកំណត់ឲ្យមានឯកសណ្ឋានច្បាស់លាស់ និងការពង្រឹងគុណភាពសេវាកម្ម
- រៀបចំបកប្រែ និងបោះពុម្ពឯកសារពិធីផ្សេងៗ និងប្រវត្តិសំខាន់ៗដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តក្រចេះទៅក្នុងបណ្តាញទំនាក់ទំនងដូចជា( គេហទំព័រទេសចរណ៍ និងទស្សនាវដ្តីជាដើម)

- សិក្សាស្រាវជ្រាវតំបន់សក្តានុពលទេសចរណ៍តាមតំបន់ធម្មជាតិ និងធ្វើការអភិវឌ្ឍតំបន់ព្រៃ ជំរកសត្វស្លាបទឹក និងជីវៈចម្រុះ និងអភិវឌ្ឍន៍ផលិតផល និងសេវាកម្មទេសចរណ៍បន្ថែម
- រៀបចំបង្កើតសហគមន៍លក់វត្ថុអនុស្សាវរីយ៍ និងផលិផលសហគមន៍ខេត្តក្រចេះ
- ជំរុញ និងលើកទឹកចិត្តដល់អ្នកវិនិយោគរៀបចំបង្កើតមជ្ឈមណ្ឌលកម្សាន្តនានា ក្នុងខេត្តក្រចេះ
- ផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ មានដូចជា សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន ភោជនីយដ្ឋាន និងកន្លែងកម្សាន្តនានា ក្នុងការពង្រឹងគុណភាពទាំងសេវា និងអនាម័យ
- បណ្តុះបណ្តាលដល់ទេសចរណ៍សហគមន៍ពីអនាម័យ និងការផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាពខ្ពស់
- រៀបចំបង្កើតកន្លែងកម្សាន្តនិងរៀបចំកញ្ចប់ដំណើរទស្សនកិច្ចទេសចរណ៍ខេត្តក្រចេះ
- សហការរៀបចំបង្កើតផ្សាររាត្រីប្រចាំខេត្តក្រចេះ
- ផលិត និងផ្សព្វផ្សាយស្ប៉តវីដេអូទេសចរណ៍ខ្លីៗពីតំបន់សក្តានុពលទេសចរណ៍ក្នុងខេត្ត និងផលិតផលទេសចរណ៍ថ្មីៗដែលបានអភិវឌ្ឍន៍តាមប្រព័ន្ធផ្សព្វផ្សាយក្នុងខេត្ត
- រៀបចំចងក្រងព័ត៌មានពីផលិតផលទេសចរណ៍ដែលបានរៀបចំថ្មីៗបន្ថែមបញ្ចូលក្នុងគេហទំព័រទេសចរណ៍នានា
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលទេសចរណ៍ (ទាំងក្នុង និងក្រៅស្រុក)
- រៀបចំព្រឹត្តិការណ៍សំខាន់ៗក្នុងខេត្ត(ការប្រគុំតន្ត្រីទេសចរណ៍ ការតាំងពិពណ៌ផលិតផល និងពិធីបុណ្យជាតិសំខាន់ៗនៅក្នុងខេត្តក្រចេះ)
- រៀបចំដំណើរទេសចរណ៍រួមគ្នា របស់ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ជាតិ និងអន្តរជាតិធំៗ និងការចូលរួមពីប្រតិបត្តិករទេសចរណ៍សំខាន់ៗ
- រៀបចំបោះពុម្ពឯកសារផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តក្រចេះ និងបកប្រែជាភាសាបរទេស។

## ៣.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- ជំរុញដោះស្រាយបញ្ហាប្រឈមនានាដើម្បីសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនទេសចរ
- ស្នើសុំឲ្យមានការអភិវឌ្ឍ និងជួសជុលផ្លូវចូលទៅកាន់រមណីយដ្ឋានមួយចំនួន ដែលមានសក្តានុពល
- សិក្សាស្រាវជ្រាវស្វែងរកដៃគូវិនិយោគរៀបចំទីចតរបស់នាវាកម្សាន្ត និងកាណូតទេសចរណ៍

- សិក្សារៀបចំទីសម្រាកទេសចរ និងបង្គន់សាធារណៈ នៅតាមតំបន់រមណីយដ្ឋាន។

### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- ស្នើសុំឲ្យមានការអភិវឌ្ឍ និងជួសជុលផ្លូវចូលទៅកាន់រមណីយដ្ឋានមួយចំនួន ដែលមានសក្តានុពល
- សិក្សាស្រាវជ្រាវ ស្វែងរកដៃគូវិនិយោគ រៀបចំទីចតរបស់នាវាកម្សាន្ត និងកាណូតទេសចរណ៍
- ជំរុញដោះស្រាយបញ្ហាប្រឈមនានា ដើម្បីសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនទេសចរ។

## ៣.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ ***ផែនការ និងវិធានការពង្រឹងសន្តិសុខសុវត្ថិភាពជូនភ្ញៀវទេសចរ***

- សហការជាមួយស្ថាប័នពាក់ព័ន្ធ នគរបាលទេសចរណ៍ក្នុងការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពដើម្បីពង្រឹងសន្តិសុខ សុវត្ថិភាពជូនភ្ញៀវតាមគោលដៅទេសចរណ៍
- សហការជាមួយមន្ទីរសុខាភិបាល និងស្ថាប័នពាក់ព័ន្ធដោយប្រើប្រាស់យន្តការ និងមូលដ្ឋានសម្ភារៈដែលមានសម្រាប់ (មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក សង្គ្រោះបឋមឲ្យបានទាន់ពេលវេលាក្នុងករណីភ្ញៀវមានគ្រោះថ្នាក់ផ្សេងៗ)
- សហការជាមួយមន្ទីរសុខាភិបាល អាជ្ញាធរដែនដី ចុះធ្វើការផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ស្តីពីការពង្រឹងគុណភាពផលិតផល សេវាកម្ម និងធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សុវត្ថិភាពក្នុងការស្នាក់នៅដើរកម្សាន្ត និងសុវត្ថិភាពចំណីអាហារ
- ណែនាំអប់រំបណ្តុះបណ្តាលដល់អ្នកបម្រើសេវាទេសចរណ៍ និងនៅតាមសហគមន៍ឲ្យទទួលបានការយល់ដឹងពីរបៀបសង្គ្រោះបឋម
- ណែនាំដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ទេសចរណ៍ឲ្យមានបំពាក់នូវឧបករណ៍សម្ភារៈ មធ្យោបាយសមស្របដើម្បីបង្ការ ជួយសង្គ្រោះបន្ទាន់ក្នុងករណីភ្ញៀវមានគ្រោះថ្នាក់
- លុបបំបាត់ភាពអនាធិបតេយ្យផ្សេងៗ និងការកេងប្រវ័ញ្ចនានាចំពោះភ្ញៀវទេសចរ
- ពង្រឹងសុវត្ថិភាពភ្ញៀវទេសចរលើការធ្វើដំណើរកម្សាន្ត ការស្នាក់នៅ ម្ចាស់សេវាកម្មទាំងឡាយត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន

- សហការជាមួយសមត្ថកិច្ចជំនាញក្នុងការគ្រប់គ្រង ពង្រឹងមូលដ្ឋានអាជីវកម្ម សេវាកម្ម ទេសចរណ៍ និងសហគមន៍មូលដ្ឋានព្រមទាំងចាត់វិធានការជាបន្ទាន់ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសុវត្ថិភាពទេសចរ។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង(២០២៣-២០២៥)

❖ ***ផែនការ និងវិធានការពង្រឹងសន្តិសុខសុវត្ថិភាពជូនភ្ញៀវទេសចរ***

- រៀបចំប្រព័ន្ធផ្តល់ព័ត៌មានទំនាក់ទំនងតាមតំបន់គោលដៅទេសចរណ៍
- សហការជាមួយមន្ទីរសុខាភិបាល និងស្ថាប័នពាក់ព័ន្ធដោយប្រើប្រាស់យន្តការមូលដ្ឋានសម្ភារៈដែលមានសម្រាប់(មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក)ត្រៀមក្នុងការសង្គ្រោះបន្ទាន់ឬបឋមឲ្យបានទាន់ពេលវេលាក្នុងករណីភ្ញៀវមានគ្រោះថ្នាក់កើតឡើងជាយថាហេតុ
- អប់រំបណ្តុះបណ្តាលដល់អ្នកបម្រើសេវាកម្មទេសចរណ៍ នៅតាមសហគមន៍ឲ្យទទួលបានការយល់ដឹងពីរបៀបសង្គ្រោះបឋម
- ណែនាំដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ទេសចរណ៍អោយមានបំពាក់នូវឧបករណ៍ សម្ភារៈនិងមធ្យោបាយសមស្របដើម្បីជួយសង្គ្រោះបន្ទាន់ក្នុងករណីភ្ញៀវមានគ្រោះថ្នាក់ផ្សេងៗ។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ ***ការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមាន***

- ជំរុញសកម្មភាពនៃការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- ជំរុញយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ និងបញ្ជ្រាបការយល់ដឹងនូវផលប៉ះពាល់នៃគ្រឿងញៀនដល់ប្រត្តិបតិករទេសចរណ៍
- ណែនាំ និងទប់ស្កាត់ការបំពុលបរិស្ថានដែលកើតពីសកម្មភាពរបស់ភ្ញៀវទេសចរ
- លុបបំបាត់ភាពអនាធិបតេយ្យផ្សេងៗ សកម្មភាពការកេងប្រវ័ញ្ចនានាចំពោះភ្ញៀវទេសចរនៅតាមតំបន់ទេសចរណ៍។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ ***ការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមាន***

- ជំរុញសកម្មភាពនៃការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
- ជំរុញសកម្មភាពក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងបញ្ជ្រាបការយល់ដឹងដល់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងខេត្ត

- ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងបញ្ជ្រាបការយល់ដឹងអំពីផលប៉ះពាល់នៃគ្រឿងញៀនដល់ប្រតិបត្តិករទេសចរណ៍ និងអ្នកបម្រើសេវា
- ណែនាំ និងទប់ស្កាត់ការបំពុលបរិស្ថានដែលកើតពីសកម្មភាពរបស់ភ្ញៀវទេសចរ
- លុបបំបាត់ភាពអនាធិបតេយ្យផ្សេងៗ និងសកម្មភាពការកេងប្រវ័ញ្ចនានាចំពោះភ្ញៀវទេសចរនៅតាមតំបន់ទេសចរណ៍។

## ៣.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- អប់រំផ្សព្វផ្សាយពីច្បាប់ទេសចរណ៍ បទបញ្ញត្តិគ្រប់គ្រងអាជីវកម្មទេសចរណ៍ និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់អាជីវករ និងសហគមន៍ទេសចរណ៍
- តាមដានត្រួតពិនិត្យតាមបណ្តាអាជីវកម្មទេសចរណ៍ និងទប់ស្កាត់សកម្មភាពអាជីវកម្មទេសចរណ៍ខុសច្បាប់ គ្មានអាជ្ញាប័ណ្ណទេសចរណ៍
- ចងក្រងទិន្នន័យពីប្រភេទអាជីវកម្មទេសចរណ៍នៅក្នុងខេត្តទាំងមូល
- ជំរុញដល់ប្រតិបត្តិករទេសចរណ៍ទាំងអស់នៅក្នុងខេត្តឱ្យចូលរួមគោរពច្បាប់ ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្ត ទាំងឡាយដែលក្រសួងបានដាក់ចេញ។

### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- អប់រំផ្សព្វផ្សាយពីច្បាប់ទេសចរណ៍ បទបញ្ញត្តិស្តីពីការគ្រប់គ្រងអាជីវកម្មទេសចរណ៍ និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់អាជីវករ និងសហគមន៍ទេសចរណ៍
- តាមដានត្រួតពិនិត្យតាមបណ្តាអាជីវកម្មទេសចរណ៍ និងទប់ស្កាត់សកម្មភាពអាជីវកម្មទេសចរណ៍ខុសច្បាប់ និងគ្មានអាជ្ញាប័ណ្ណទេសចរណ៍
- ជំរុញដល់អ្នកប្រតិបត្តិករទេសចរណ៍ទាំងអស់នៅក្នុងខេត្តឱ្យចូលរួមគោរពច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តទាំងឡាយដែលក្រសួងបានដាក់ចេញ។

## ៣.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រ

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ *ពង្រឹងសមត្ថភាពមន្ត្រី*

- ពង្រឹងឱ្យមានការប្រជុំរបស់មន្ត្រីរាជការជាប្រចាំដូចជាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងមន្ទីរទេសចរណ៍តាមរយៈការជំរុញក្នុងការចូលរួមវគ្គបណ្តុះបណ្តាលឬសិក្ខាសាលានានាឱ្យត្រឹមត្រូវតាមជំនាញ

- ពង្រឹងសមត្ថភាពមន្ត្រីក្របខណ្ឌ និងមន្ត្រីកិច្ចសន្យា តាមរយៈការចែករំលែកនូវបទ-ពិសោធន៍ ការរៀនសូត្រ និងការបង្រៀនគ្នាទៅវិញទៅមក
- ពង្រឹងការអនុវត្តច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ ***ពង្រឹងសមត្ថភាពមន្ត្រី***

- ពង្រឹងឲ្យមានការប្រជុំរបស់មន្ត្រីរាជការជាប្រចាំដូចជា ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងមន្ទីរទេសចរណ៍តាមរយៈការជំរុញក្នុងការចូលរួមវគ្គបណ្តុះបណ្តាលឬសិក្ខាសាលានានាឱ្យត្រឹមត្រូវតាមជំនាញ
- ពង្រឹងសមត្ថភាពមន្ត្រីក្របខណ្ឌ និងមន្ត្រីកិច្ចសន្យា តាមរយៈការចែករំលែកនូវបទ-ពិសោធន៍ ការរៀនសូត្រ និងការបង្រៀនគ្នាទៅវិញទៅមក
- ពង្រឹងការអនុវត្តច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ ***ធនធានមនុស្សក្នុងឧស្សាហកម្មទេសចរណ៍***

- ជំរុញដល់ម្ចាស់អាជីវកម្មនៅក្នុងវិស័យទេសចរណ៍ចាត់បញ្ជូនបុគ្គលិកដែលបម្រើសេវាចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែលរៀបចំដោយក្រសួង មន្ទីរ ឬអង្គការដៃគូក្រៅរដ្ឋាភិបាល
- បំផុសឲ្យមានការយល់ដឹងអំពីភាពស្អាតនៅក្នុងទីក្រុង រមណីយដ្ឋាន និងតំបន់ទេសចរណ៍ទូទាំងខេត្ត ព្រមទាំងជំរុញឲ្យមានការអនុវត្តលើការបម្រើសេវាល្អ និងបដិសណ្ឋារកិច្ចល្អក្នុងគោលបំណងរក្សានូវគុណតម្លៃ សុខភាព សោភណ្ឌភាព និងបទពិសោធន៍ដ៏ល្អសម្រាប់ភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិ។

## ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ ***ធនធានមនុស្សក្នុងឧស្សាហកម្មទេសចរណ៍***

- បណ្តុះបណ្តាលបុគ្គលិកក្នុងវិស័យឧស្សាហកម្មទេសចរណ៍ឲ្យមានជំនាញគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការនៃកំណើនទេសចរ ជាពិសេសដើម្បីត្រៀមទទួលទេសចរជាតិ និងអន្តរជាតិដែលមកកម្សាន្តនៅក្នុងខេត្តក្រចេះក្នុងឱកាសដែលកម្ពុជាយើងទទួលធ្វើជាម្ចាស់ផ្ទះនៃកីឡា**អាស៊ានហ្គេម**(Asian Game) នៅក្នុងឆ្នាំ២០២៣។

## ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

❖ ***សមត្ថភាពយេនឌ័រក្នុងវិស័យទេសចរណ៍***

- អប់រំ និងលើកកម្ពស់សមធម៌យេនឌ័រចូលរួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍
- លើកទឹកចិត្តក្នុងការពង្រីកចំណេះដឹងដល់ស្ត្រីជាមន្ត្រីនៅក្នុងអង្គភាព

- លើកទឹកចិត្តឲ្យស្ត្រីមានតួនាទីក្នុងការដឹកនាំនៅក្នុងអង្គភាព
- ជំរុញចងក្រងក្រុមយេនឌ័រ នៅតាមបណ្តាមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍
- រៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។

### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

❖ *សមត្ថភាពយេនឌ័រក្នុងវិស័យទេសចរណ៍*

- អប់រំ និងលើកកម្ពស់សមភាពយេនឌ័រចូលរួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍
- លើកទឹកចិត្តក្នុងការពង្រីកចំណេះដឹងដល់ស្ត្រីជាមន្ត្រីនៅក្នុងអង្គភាព
- លើកទឹកចិត្តឲ្យស្ត្រីមានតួនាទីក្នុងការដឹកនាំនៅក្នុងអង្គភាព
- ជំរុញចងក្រងក្រុមយេនឌ័រនៅតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍
- ចុះផ្សព្វផ្សាយ បណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។

## ៣.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍

### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- ជំរុញដល់ការវិនិយោគផ្នែកសណ្ឋាគារលំដាប់ផ្កាយ ប្រកបដោយគុណភាពសម្រាប់បំពេញបន្ថែមពីតម្រូវការទេសចរ
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការរៀបចំភោជនីយដ្ឋាន អាហារដ្ឋានដែលប្រកបដោយស្តង់ដា និងមានគុណភាពខ្ពស់ប្រចាំខេត្ត
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគ ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុកដើម្បីរៀបចំកន្លែងកម្សាន្តនៅក្នុងខេត្ត ជាពិសេសក្រុងក្រចេះដូចជាបង្កើតឲ្យមានជាផ្សាររាត្រី វិថីលក់ម្ហូបអាហារជាដើម។

### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- ជំរុញការវិនិយោគផ្នែកសណ្ឋាគារលំដាប់ផ្កាយ ប្រកបដោយគុណភាពសម្រាប់បំពេញបន្ថែមពីតម្រូវការទេសចរ
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការរៀបចំភោជនីយដ្ឋានអាហារដ្ឋានដែលមានស្តង់ដា និងមានគុណភាពខ្ពស់ប្រចាំខេត្ត
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគ ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុកដើម្បីរៀបចំកន្លែងកម្សាន្តនៅក្នុងខេត្តជាពិសេសក្រុងក្រចេះដូចជាបង្កើតឲ្យមានផ្សាររាត្រី និងវិថីលក់ម្ហូបអាហារជាដើម។

### ៣.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

#### ក. ផែនការសម្រាប់អនុវត្តរយៈពេលខ្លី (២០២១-២០២២)

- សហការការពារអភិរក្សធនធានវប្បធម៌ដែលមានស្រាប់របស់ខេត្តក្រចេះជាអាទិ៍របាំវប្បធម៌ ប្រពៃណីជនជាតិដើមភាគតិច
- អប់រំប្រជាពលរដ្ឋ ស្តីពីផលប៉ះពាល់អវិជ្ជមាននានាលើបរិស្ថាន និងធនធានធម្មជាតិ
- រៀបចំឲ្យមានឆ្នាំការពារធនធានធម្មជាតិ និងបរិស្ថាននៅតាមតំបន់រមណីយដ្ឋាន
- ចូលរួមដាំដើមឈើឡើងវិញនៅតាមតំបន់ទេសចរណ៍នានាក្នុងខេត្ត។

#### ខ. ផែនការសម្រាប់អនុវត្តរយៈពេលវែង (២០២៣-២០២៥)

- សហការការពារ និងអភិរក្សធនធានវប្បធម៌ដែលមានស្រាប់របស់ខេត្តក្រចេះជាអាទិ៍របាំ វប្បធម៌ប្រពៃណីជនជាតិដើមភាគតិច
- អប់រំប្រជាពលរដ្ឋស្តីពីផលប៉ះពាល់អវិជ្ជមាននានាចំពោះធនធានធម្មជាតិ និងបរិស្ថាន
- រៀបចំឲ្យមានឆ្នាំការពារធនធានធម្មជាតិ និងបរិស្ថាននៅតាមតំបន់រមណីយដ្ឋាន
- ចូលរួមដាំដើមឈើឡើងវិញនៅតាមតំបន់ទេសចរណ៍នានាក្នុងខេត្ត។

## VI. ធនធានហិរញ្ញវត្ថុ

ផែនការការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តក្រចេះ ពិតជាមានសារៈសំខាន់ក្នុងការបង្ហាញផ្លូវឆ្ពោះទៅរកការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយភាពជោគជ័យ និងមាននិរន្តរភាព។ ប្រភពថវិកាស្វែងរកបានដើម្បីទ្រទ្រង់ការអនុវត្តផែនការអភិវឌ្ឍន៍ទេសចរណ៍៥ឆ្នាំរបស់រដ្ឋបាលខេត្តក្រចេះក្នុងវិស័យទេសចរណ៍ខាងលើនេះអាចបានមកពីថវិការដ្ឋ ថវិកាជំនួយដៃគូអភិវឌ្ឍន៍ ថវិកាបានមកពីការចូលរួមរបស់ប្រតិបត្តិករក្នុងតំបន់ ថវិកាវិនិយោគរបស់វិស័យឯកជន និងប្រភពថវិការួមតាមរយៈការបញ្ចូលផែនការសកម្មភាពទៅក្នុងផែនការអភិវឌ្ឍន៍ខេត្តផ្ទាល់ ។

## VII. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការបង្កើតឲ្យមាននូវយន្តការមួយក្នុងការធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់អ្នកអនុវត្តផ្ទាល់ដែលអាចមើលឃើញយ៉ាងច្បាស់លាស់នូវលទ្ធផលការងារជាវិជ្ជមាន និងអវិជ្ជមានរាល់សកម្មភាពដែលបាន និងកំពុងអនុវត្តងាយស្រួលក្នុងការកែតម្រូវទាន់ពេលវេលា។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះ ចាំបាច់ត្រូវអនុលោមតាមផែនការសកម្មភាពដែលបានរំលេចឡើងនៅក្នុងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម៥ឆ្នាំរបស់ខេត្តក្រចេះ ដោយកំណត់ជាដំណាក់កាលៗ ឲ្យបានច្បាស់លាស់។

លើសពីនេះទៅទៀតនោះ ការរៀបចំទម្រង់របាយការណ៍ជាប្រចាំរួមមានដូចជាៈ ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំជាកត្តាមួយដែលមានលក្ខណៈល្អប្រសើរសម្រាប់ជាឧបករណ៍តាមដាន និងវាយតម្លៃអំពីលទ្ធផលការងារសកម្មភាពដែលបានអនុវត្ត។ ការចុះត្រួតពិនិត្យផ្ទាល់ជាប្រចាំទៅដល់ទីកន្លែងដែលបានអនុវត្តសកម្មភាព វាក៏ជាយុទ្ធសាស្ត្រមួយដ៏សំខាន់ដែរក្នុងការពិនិត្យតាមដាន និងវាយតម្លៃផែនការអភិវឌ្ឍន៍ទេសចរណ៍ខាងលើនេះដែរ។

គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ ដោយសហការជាមួយក្រសួងទេសចរណ៍ត្រូវធ្វើការដឹកនាំប្រជុំពិនិត្យវាយតម្លៃលទ្ធផលការអនុវត្តការងារអភិវឌ្ឍន៍ទេសចរណ៍ខាងលើជារៀងរាល់៦ខែម្តង និងកិច្ចប្រជុំវិសាមញ្ញផ្សេងៗតាមការចាំបាច់។ នៅរៀងរាល់ចុងឆ្នាំនីមួយៗត្រូវធ្វើការបូកសរុបលទ្ធផលការងារអនុវត្ត និងរាយការណ៍ជូនខេត្ត ក្រសួង និងស្ថាប័នពាក់ពន្ធ័នានា។ នៅក្នុងឆ្នាំ២០២៣ដែលជាឆ្នាំពាក់កណ្តាលអាណត្តិនៃផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ តម្រូវឲ្យមានការរៀប-ចំប្រជុំធំមួយដោយមានការចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ ដើម្បីវាយតម្លៃលទ្ធផលដែលបានអនុវត្តក្នុងរយៈពេល២ឆ្នាំកន្លះ ហើយថាផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម៥ឆ្នាំនេះអាចត្រូវបានធ្វើការកែសម្រួលតាមសភាពភាពជាក់ស្តែងដោយមានការពិនិត្យ និងវាយតម្លៃពីគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ។

## VIII. សេចក្តីសន្និដ្ឋាន

វិស័យទេសចរណ៍ត្រូវបានចាត់ទុកថាជាវិស័យអាទិភាពមួយក្នុងការរួមចំណែកកសាងសេដ្ឋកិច្ច សង្គម ថែរក្សាការពារ អភិរក្សធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងលើកកម្ពស់កិត្យានុភាពរបស់ខេត្ត ក្នុងតំបន់ និងលើឆាកអន្តរជាតិ។ វិស័យទេសចរណ៍ក្រៅពីផ្តល់នូវសារៈសំខាន់ក្នុងដំណើរលំហែកាយ និងផ្តល់ភាពសប្បាយរីករាយ វាក៏បានផ្តល់ចំណេះដឹង ការស្វែងយល់ពីទំនៀមទំលាប់ប្រពៃណី បទពិសោធន៍ថ្មីៗ ព្រមទាំងការផ្តល់នូវទំនាក់ទំនងមិត្តភាព។ ខេត្តក្រចេះ ត្រូវបានគេទទួលស្គាល់ថាជាខេត្តមានសក្តានុពលទេសចរណ៍បែបធម្មជាតិ ភាពសំបូរបែបនៃធនធានធម្មជាតិដែលមានក្នុងតំបន់។

គោលជំហររបស់ខេត្តក្រចេះ គាំទ្រយ៉ាងពេញទំហឹងក្នុងការជួយជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តឲ្យមានការរីកចម្រើន និងប្រកបដោយនិរន្តរភាព។ ការបង្កើតផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្ន-កម្ម២០២១-២០២៥ខេត្តក្រចេះ នឹងផ្តល់នូវគុណប្រយោជន៍យ៉ាងធំធេងដល់ដំណើរការអភិវឌ្ឍខេត្តទាំងមូល ដោយហេតុថាការអភិវឌ្ឍវិស័យទេសចរណ៍គឺមានលក្ខណៈជាប្រព័ន្ធ ហើយអាចជួយជំរុញដល់ការអភិវឌ្ឍវិស័យនានារួមគ្នាបង្កើនល្បឿនអភិវឌ្ឍស្របតាមផែនការអភិវឌ្ឍន៍ទាំងមូលរបស់រដ្ឋបាលខេត្ត។

សរុបសេចក្តីមក ដើម្បីសម្រេចឲ្យបានគោលដៅលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តក្រចេះ គឺតម្រូវឲ្យមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលខេត្តផ្ទាល់នូវផែន-ការសកម្មភាពដែលបានលើកឡើងខាងលើ ព្រមទាំងជួយជ្រោមជ្រែងថវិកា និងការជួយជំរុញឲ្យមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងខេត្ត ដៃគូអភិវឌ្ឍន៍វិស័យឯកជន និងប្រជាពលរដ្ឋផងដែរ។

## IX. ឯកសារយោង

1) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា
2) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា
3) គោលការណ៍ណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត ឆ្នាំ ២០១៩ - ២០២៣
4) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្រចេះ ២០១៥-២០១៩
5) ច្បាប់ស្តីពីទេសចរណ៍លេខនស/រកត/០៦០៩/០០៧
6) គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០
7) គោលនយោបាយជាតិលើវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា
8) ផែនការវិនិយោគ៣ឆ្នាំរំកិល ខេត្តក្រចេះ
9) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ក្នុងតំបន់អភិរក្សសត្វក្តាន់ និងតំបន់អភិរក្សសត្វស្លាបនៃតំបន់ការពារទេសភាពព្រៃលិចទឹកទន្លេមេគង្គខេត្តក្រចេះ ដោយលោក បណ្ឌិត នេត បារមី និងលោកស្រីបណ្ឌិត វិត សំអុល
10) របាយការណ៍ស្រាវជ្រាវស្តីពីប្លង់គោលអភិវឌ្ឍន៍ទេសចរណ៍ក្រុងក្រចេះ ឆ្នាំ២០០៧ ដោយគម្រោងអភិវឌ្ឍន៍ផ្លូវទស្សនាមេគង្គ

គាំទ្រដោយ ÷

WWF

Belgium
partner in development